# ប្រាសាទព្រះវិហារខ្មែរ និងមហិច្ឆតាឈ្លានពានរបស់សៀម : អតីតកាល និង បច្ចុប្បន្នកាល

ចូលមកដល់សតវត្សរ៍ទី ១១ ប្រទេសកម្ពុជាបានក្លាយទៅជាមហាអំណាចមួយយ៉ាងធំនៅអាស៊ីអាគ្នេយ៍។ ការសាងសង់ប្រាង្គប្រាសាទធំៗ ក៏មានច្រើនសឹងគ្រប់ទិសទីលើទឹកដីខ្មែរ។ ក្នុងចំណោមប្រាង្គប្រាសាទល្អល្អះទាំងនោះ មាន *ប្រាសាទព្រះវិហារ* ដែលកសាងលើកំពូលភ្នំដងរែក ដែលពីដើមឡើយ មានឈ្មោះថា *ភ្នំកំផែង* ។ ភ្នំដងរែក ឬភ្នំកំផែង មានកម្ពស់ប្រមាណ ៦២៥ ម៉ែត្រ ហើយបច្ចុប្បន្នស្ថិតនៅក្នុងខេត្តព្រះវិហារ នៃភាគឧត្តរប្រទេសកម្ពុជា។

ប្រាសាទព្រះវិហារត្រូវបានចាត់ទុកជាសំណង់ស្ថាបត្យកម្មដ៏ប្រណីតក្នុងលោក ដែលកម្រមាន។ សំណង់ស្ថាបត្យកម្មដ៏ប្រណីតលើកំពូលភ្នំនេះ គឺជាទីប្រជុំបារមីល្បីមហិមា គ្រប់គ្រងដែនកម្ពុជាពីជើងទៅត្បូង ក្រោមឫទ្ធិលិង្គព្រះភ័ក្ត្រត្រៃស្វារៈ ដែលសិលាចារឹកបានបញ្ជាក់ថា បានដង្ហែយកពីទីក្រុងអង្គរ។ ប្រាសាទនេះ បានឆ្លាក់ឱ្យឃើញគ្រប់បែបបទ ចងជាអំណាចទិព្វមណ្ឌលសាធារណៈសម្រាប់ព្រះរាជាស្នងរាជ្យក្រោយៗ ឱ្យថែរក្សាវាសនាជាតិកុំឱ្យរលាយសាបសូន្យ។

ប្រទេសសៀម ដែលជាអ្នកជិតខាងកម្ពុជា តែងមានមហិច្ឆតា រំលោភកាន់កាប់ប្រាសាទព្រះវិហារដោយខុសច្បាប់ម្ដងហើយម្ដងទៀត តាំងពីឆ្នាំ ១៩៤១ មក ទោះបីប្រទេសនេះដឹងថា ប្រាសាទព្រះវិហារស្ថិតក្នុងដែនអធិបតេយ្យរបស់កម្ពុជាដោយស្របច្បាប់ក៏ដោយ។ សន្និសញ្ញា និងអនុសញ្ញាជាច្រើន ដែលយើងលើកឡើងក្នុងអត្ថបទនេះ ជាពិសេស សាលក្រមតុលាការយុត្តិធម៌អន្តរជាតិ ក្រុងឡាអេ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៦២ និងការសម្រេចរបស់គណៈកម្មការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ កាលពីថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ គឺបានបង្ហាញយ៉ាងច្បាស់ថា ប្រាសាទព្រះវិហារស្ថិតក្នុងដែនអធិបតេយ្យរបស់កម្ពុជា។ ប៉ុន្តែសៀមមិនបានបោះបង់មហិច្ឆតារបស់ខ្លួន ក្នុងការកាន់កាប់ប្រាសាទព្រះវិហារនោះទេ។

ក្នុងអត្ថបទនេះ យើងសូមលើកឡើងនូវសន្ធិសញ្ញា អនុសញ្ញានានា ដែលពាក់ព័ន្ធនឹងព្រំប្រទល់ដែនខ្មែរជាមួយប្រទេសសៀម ប្រវត្តិប្រាសាទព្រះវិហារ រឿងក្ដីប្រាសាទព្រះវិហារកាលបរិច្ឆេទ និងសកម្មភាពខ្លះៗ ទាក់ទងនឹងកិច្ចប្រជុំអនុម័តប្រាសាទព្រះវិហារ ចូលជាបេតិកភណ្ឌពិភពលោក ជម្លោះក្រោយថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨ ដំណើរការចរចា និងមហិច្ឆតារបស់សៀម ដើម្បីទុកជាឯកសារសម្រាប់អ្នកសិក្សាស្រាវជ្រាវពិចារណា ទៅថ្ងៃក្រោយ។

## *ប្រវត្តិប្រាសាទព្រះវិហារ*

ប្រាសាទព្រះវិហារជារមណីយដ្ឋានប្រវត្តិសាស្ត្រ ដែលពីដើមមានឈ្មោះថា "**ស្រីសិខរីស្វារៈ**" ដែលប្រែថា "**បារមីភ្នំ**"។ បើតាមសៀវភៅស្ដីពី កំណត់បញ្ហាព្រះវិហាររបស់គណៈបេសកកម្មអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ ប្រាសាទព្រះវិហារ មានន័យថា "**បុគ្គលជាទីគោរព**" ឬមានន័យថា "**អារាមជាទីគោរព**"។

ប្រាសាទនេះបានកសាងឡើងចាប់ពីសតវត្សរ៍ទី ៩ ដល់សតវត្សរ៍ទី ១២ ដោយព្រះរាជា ៤ ព្រះអង្គ គឺ *ព្រះបាទយសោវរ្ម័នទី ១* (គ.ស៨៨៩-៩១០) ព្រះអង្គកសាងប្រាសាទកណ្ដាល។ *ព្រះបាទសូរ្យវរ្ម័នទី ១* (គ.ស ១០០២-១០៥០) ព្រះអង្គកសាងប្រាសាទយ៉ាងវែងនៅជិតប្រាសាទកណ្ដាល និងកសាងកំពែងព័ទ្ធជុំវិញ និងកសាងគោបុរៈបី។ *ព្រះបាទជ័យវរ្ម័នទី ៦* (គ.ស ១០៨០-១១០៩) ព្រះអង្គបានកសាងបណ្ណាល័យពីរ និងជួសជុលផ្នែកមួយចំនួននៃប្រាសាទព្រះវិហារ។ *ព្រះបាទសូរ្យវរ្ម័នទី ២* (គ.ស ១១១៣ -១១៥០) ព្រះអង្គបានសាងសង់ព្រលាន ដែលមាននាគក្បាលប្រាំពីរ រូបតោតាមផ្លូវ និងរូបនាគជាច្រើនទៀត តាមជណ្ដើរឡើង។[១]

នៅសម័យអង្គរ **ប្រាសាទព្រះវិហារ** ស្ថិតនៅតំបន់កណ្ដាលនៃចក្រភពខ្មែរ។ បច្ចុប្បន្ន ប្រាសាទព្រះវិហារមានទីតាំងស្ថិតនៅលើជួរភ្នំដងរែក ក្នុងភូមិស្វាយជ្រំ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ[២]។ ប្រាសាទព្រះវិហារមានទំហំបណ្ដោយ ៨០០ ម៉ែត្រ និងទទឹង ៤០០ ម៉ែត្រ ស្ថិតនៅលើភ្នំព្រះវិហារ ដែលមានកម្ពស់ ៦២៥ ម៉ែត្រ មានចំណោទខ្លាំងពីប្រទេស

[១] កំណត់បញ្ហាព្រះវិហារ គណៈបេសកកម្មអចិន្ត្រៃយ៍នៃប្រទេសកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ ឆ្នាំ១៩៥៧។

[២] ខេត្តព្រះវិហារត្រូវបានបង្កើតឡើងតាមព្រះរាជក្រមលេខ ១៩៤-ប.រ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៦៤ នៅក្នុងរាជកិច្ចលេខ ៥៧ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ១៩៦៤ ទំព័រ៥៨៥០-៥៨៥២។ ខេត្តនេះមាន ៤ ស្រុក ដែលក្នុងនោះ ៣ ស្រុក ត្រូវផ្ដាច់ចេញពីខេត្តកំពង់ធំ គឺ ស្រុករវៀង ស្រុកឆែប និងស្រុកជាំក្សាន្ត ហើយមួយស្រុកទៀត គឺស្រុកអង្គរជុំ ដែលមានចំនួន ៣ ឃុំ ត្រូវផ្ដាច់ចេញពីខេត្តសៀមរាប។ ទីរួមខេត្តព្រះវិហារ ស្ថិតនៅត្បែងមានជ័យ។

កម្ពុជា និងរាងទេរពីប្រទេសសៀម ។ ប្រាសាទនេះ មានចម្ងាយ ១០៦ គីឡូម៉ែត្រ ពីទីរួមខេត្តព្រះវិហារ ។




ចក្រភពខ្មែរ សម័យអង្គរ

ចំពោះ ការធ្វើដំណើរទៅកាន់ប្រាសាទព្រះវិហារសព្វថ្ងៃនេះ គេអាចទៅមកបានតាមផ្លូវចំនួន ៣ គឺតាមផ្លូវភ្នំដែក ដែលគិតពីផ្លូវបំបែកកំពង់ធំ ទៅដល់ប្រាសាទព្រះវិហារមានចម្ងាយ ២៦៣ គីឡូម៉ែត្រ ។ តាមផ្លូវដំដែកគិតពីផ្លូវជាតិលេខ ៦ ដល់ប្រាសាទព្រះវិហារមានចម្ងាយ ២០៦ គីឡូម៉ែត្រ និងតាមផ្លូវអន្លង់វែង គិតពីខេត្តសៀមរាបដល់ប្រាសាទព្រះវិហារ មានចម្ងាយ ២៤០ គីឡូម៉ែត្រ ។ ដោយឡែក ផ្លូវឡើងភ្នំប្រាសាទព្រះវិហារចាប់ពីជើងភ្នំ (ភូមិ គ១) ដល់ប្រាសាទព្រះវិហារមានចម្ងាយប្រមាណជា ៤ គីឡូម៉ែត្រ ដែលសព្វថ្ងៃកន្លែងខ្លះបានចាក់ក្រាលបេតុងរួច តែភាគច្រើនបានខូចទៅវិញដោយសារទឹកហូរច្រោះ ។

***សន្ធិសញ្ញា អនុសញ្ញាពាក់ទងនឹងខ្មែរ បារាំង សៀម***

ដើម្បីពិនិត្យមើលទិដ្ឋភាពប្រវត្តិសាស្ត្រ ទាក់ទងទៅនឹងប្រាសាទព្រះវិហារ យើងសូមលើកយកសន្ធិសញ្ញា និងអនុសញ្ញាពាក់ព័ន្ធមួយចំនួនរវាងប្រទេសខ្មែរ-បារាំង និងបារាំងសៀម ដូចតទៅ÷

- **សន្ធិសញ្ញាបារាំង-ខ្មែរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៨៦៣**

សន្ធិសញ្ញានេះ តម្រូវឱ្យព្រះចៅអធិរាជបារាំងផ្ដល់នូវកិច្ចការពារចំពោះព្រះរាជាកម្ពុជា ហើយព្រះចៅអធិរាជបារាំង




ផែនទីទីតាំង និងរយៈចម្ងាយផ្លូវទៅកាន់ប្រាសាទព្រះវិហារ



ទិដ្ឋភាពប្រាសាទព្រះវិហារ (មើលពីលើ)

នឹងតែងតាំងរេស៊ីដង់បារាំង ១ នាក់នៅអមព្រះរាជាកម្ពុជា ដោយមានភារកិច្ចពិនិត្យការអនុវត្ត ដោយម៉ឺងម៉ាត់នូវខ្លឹមសារសន្ធិ-សញ្ញាអាណាព្យាបាល ។ ព្រះរាជាកម្ពុជា នឹងអាចតែងតាំងរេស៊ីដង់ខ្មែរ ១ នាក់នៅក្រុងព្រៃនគរ ដើម្បីទាក់ទងផ្ទាល់ជាមួយទេសាភិបាលកូសាំងស៊ីន ។ សន្ធិសញ្ញានេះ បានបញ្ចប់ឥទ្ធិពលប្រទេសសៀមមកលើប្រទេសកម្ពុជា ។

- **សន្ធិសញ្ញា ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៨៦៧**

តាមរយៈសន្ធិសញ្ញានេះ ព្រះរាជាសៀមទទួលស្គាល់ជាឱឡារិកនូវរបបអាណាព្យាបាលរបស់ព្រះចៅអធិរាជបារាំងលើប្រទេសកម្ពុជា ។ សន្ធិសញ្ញា ដែលត្រូវបានចុះហត្ថលេខា នៅខែ ធ្នូ ឆ្នាំ ១៨៦៣ រវាងព្រះរាជាណាចក្រសៀម និងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាសជាមោឃៈ ដោយរដ្ឋាភិបាលសៀមមិនអាចលើកយកមកសំអាងនៅពេលអនាគតក្នុងកាលៈទេសៈណាក៏ដោយ ។

សន្ធិសញ្ញានេះ តម្រូវឱ្យព្រះរាជាសៀម លែងទទួលរាល់សួយសាអាករ វត្ថុអនុស្សាវរីយ៍ ឬសញ្ញាផ្សេងទៀតនៃភាពជាចំណុះពីសំណាក់ប្រទេសកម្ពុជា សម្រាប់ព្រះអង្គ ឬអ្នកស្នងរាជ្យនានារបស់ព្រះអង្គ។ ចំណែក ព្រះចៅអធិរាជបារាំងវិញ សន្យាថា នឹងមិនដណ្ដើមយករាជាណាចក្រនេះទៅបញ្ចូលក្នុងទឹកដីជាកម្មសិទ្ធិរបស់ខ្លួននៅកូសាំងស៊ីនឡើយ ។

ជាមួយគ្នានេះដែរ ខេត្តបាត់ដំបង (ណាក្លាវ) និងអង្គរ (សៀមរាប) នឹងស្ថិតនៅក្នុងរាជាណាចក្រសៀម ។ ព្រំប្រទល់នៃខេត្តនេះ និងខេត្តផ្សេងៗទៀត នៅជាប់អាណាខេត្តសៀម ដែលមានការទទួលស្គាល់ទៅវិញទៅមកនោះ នឹងត្រូវកំណត់ដោយបង្គោលព្រំដែន ឬដោយសញ្ញាផ្សេងៗទៀត ដោយគណៈ-កម្មការមួយ មានសមាសភាពនាយទាហានសៀម និងខ្មែរ ដោយមានវត្តមាន និងជំនួយពីនាយទាហានបារាំង ដែលចាត់តាំងដោយទេសាភិបាលកូសាំងស៊ីន ។ល ។

នៅក្នុងសន្ធិសញ្ញានេះ គឺបារាំងបានប្រគល់ខេត្តបាត់ដំបង និងសៀមរាប ឱ្យទៅប្រទេសសៀម ។

- **សន្ធិសញ្ញាបារាំង-សៀម ចុះថ្ងៃទី ៣ តុលា ១៨៩៣**

ប្រទេសសៀមឈប់កាន់កាប់ទឹកដីទាំងអស់ ដែលស្ថិតនៅត្រើយខាងកើតនៃទន្លេមេគង្គ និងនៅលើកោះទាំងឡាយនៃទន្លេនោះ មានន័យថា សៀមបានប្រគល់ខេត្តស្ទឹងត្រែង មកឱ្យខ្មែរវិញ។ ប្រទេសសៀមក៏បានសន្យាថាមិនដាក់កងកម្លាំងទ័ពអ្វីទាំងអស់នៅក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាប ។

- **អនុសញ្ញាបារាំង-សៀម ថ្ងៃទី ១៣ កុម្ភៈ ១៩០៤**

អនុសញ្ញានេះហើយដែលមានការជាប់ទាក់ទងនឹង រឿងក្ដីប្រាសាទព្រះវិហារនៅពេលក្រោយមក។ តាមអនុសញ្ញានេះ សៀមត្រូវប្រគល់ខេត្តម្លូព្រៃ និងទន្លេរពៅ ដែលស្ថិតនៅត្រើយខាងលិចនៃទន្លេមេគង្គ មកឱ្យខ្មែរ និងត្រូវបោះបង់បញ្ហាការលើកងតម្រួតនៅខេត្តបាត់ដំបង ស៊ីសុផុន និងសៀមរាប (ដោយត្រូវប្រគល់មកឱ្យនាយទាហានបារាំងម្ដង)។ គួរបញ្ជាក់ថា តាមអនុសញ្ញា ឆ្នាំ ១៩០៤ នេះ ពួកសៀមបានសុខចិត្តដកថយព្រំដែនទៅខាងជើងរហូតដល់ភាគខាងកើត នៃជួរភ្នំដងរែកទៀតផង ហើយសៀមក៏បានប្រគល់ខេត្តត្រាត ដែលជាខេត្តខ្មែរនៅតំបន់ឆ្នេរសមុទ្រ មកឱ្យបារាំងគ្រប់គ្រងវិញ។

- **សន្ធិសញ្ញាបារាំង-សៀម ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩០៧**

សន្ធិសញ្ញានេះ តម្រូវឱ្យរដ្ឋាភិបាលសៀមប្រគល់ឱ្យបារាំងនូវទឹកដីបាត់ដំបង សៀមរាប និងស៊ីសុផុន ដែលព្រំដែនត្រូវកំណត់ដោយ "ខ" ទី១ នៃពិធីសារស្ដីពីការកំណត់ព្រំដែន ហើយរដ្ឋាភិបាលបារាំងព្រមប្រគល់ឱ្យសៀម នូវទឹកដីដានសាយ និងក្រាត (ត្រាត) ដែលព្រំដែនត្រូវកំណត់ដោយ "ខ" ទី ១ និងទី ២ នៃពិធីសារខាងលើ ព្រមទាំងកោះទាំងអស់ ដែលស្ថិតនៅខាងត្បូងជ្រោយ "ឡិមលិង" (Lemling) រហូតទៅដល់ និងរាប់បញ្ចូលទាំងកោះគុត (Koh Kut)។ ការប្រគល់ទឹកដីទាំងនោះ ត្រូវប្រព្រឹត្តទៅទាំងសងខាង ក្នុងអំឡុងពេល ២០ ថ្ងៃ ក្រោយពេលសន្ធិសញ្ញានោះ បានទទួលសច្ចាប័ន ។

សន្ធិសញ្ញានេះក៏បានចែងថា ការកំណត់ព្រំដែនជាក់លាក់នៃដែនដីទាំងឡាយ ដែលប្រគល់ឱ្យមកនោះ ត្រូវគណៈកម្មការចម្រុះជាអ្នកធ្វើ ក្នុងរយៈពេល ៤ ខែ ក្រោយការឱ្យសច្ចាប័នលើសន្ធិសញ្ញា។

- **អនុសញ្ញា ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩២៦**

អនុសញ្ញានេះ សម្រេចកំណត់ព្រំដែនខាងទន្លេមេគង្គ រវាងសៀម និងប្រទេសឥណ្ឌូចិន ហើយបង្កើតឱ្យមានសហ-ប្រតិបត្តិការមួយ រវាងប្រទេសទាំងពីរ ខាងមុខក្រុមព្រះនគរបាល និងខាងសន្តិសុខនៅតាមទន្លេ។

- **សន្ធិសញ្ញាមិត្តភាពខាងពាណិជ្ជកម្ម និងនាវាចរ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៣៧**

សន្ធិសញ្ញានេះបញ្ជាក់បន្ថែមជាថ្មី លើព្រំប្រទល់ដែនខ្មែរសៀម ដែលបានកំណត់ទុករួចហើយពីមុន ព្រមទាំងរក្សាទុកឱ្យនៅជាធរមានយ៉ាងដាច់ខាតចំពោះអនុសញ្ញា ឆ្នាំ ១៩០៤ និងសន្ធិសញ្ញា ឆ្នាំ ១៩០៧។

- **អនុសញ្ញាសន្តិភាពរវាងប្រទេស បារាំង-សៀម ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ១៩៤១**

អនុសញ្ញានេះ បានទទួលការចុះហត្ថលេខា នៅទីក្រុងតូក្យូ តាមកិច្ចអន្តរាគមន៍ពីប្រទេសជប៉ុន ដែលតម្រូវឱ្យមាន "យុទ្ធ-សន្តិភាព" ដើម្បីបញ្ឈប់ការប្រទូសរ៉ាយ ដែលប្រទេសសៀមបានប្រព្រឹត្តប្រឆាំងនឹងកម្ពុជា គឺថាប្រឆាំងនឹងអាណាព្យាបាលបារាំងនេះឯង ក្នុងខែវិច្ឆិកា ឆ្នាំ ១៩០៤។

តាមអនុសញ្ញានេះ រដ្ឋាភិបាលបារាំង ដោយមានការបង្ខិតបង្ខំពីប្រទេសជប៉ុន បានលះបង់ចោលនូវខេត្តខ្មែរខាងលិច គឺខេត្តបាត់ដំបង ខេត្តកំពង់ធំមួយភាគខេត្ត ស្ទឹងត្រែង និងខេត្តសៀមរាប។ ហេតុដូច្នេះ អនុសញ្ញានេះ បានកែប្រែព្រំប្រទល់រវាងឥណ្ឌូចិន និងប្រទេសសៀម ។

- **កិច្ចព្រមព្រៀង បារាំង-សៀម ចុះថ្ងៃទី ១៧ វិច្ឆិកា ឆ្នាំ១៩៤៦**

កិច្ចព្រមព្រៀងនេះ បានចុះហត្ថលេខានៅក្រុងវ៉ាស៊ីនតោន ដោយបានរំលាយចោលនូវអនុសញ្ញា ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ១៩៤១ ដែលរដ្ឋាភិបាល បារាំងបានបដិសេធចោលក្នុងពេលមុន ហើយបង្កើតឡើងសារជាថ្មី នូវច្បាប់ចាស់ ដែលកើតមានមុនអនុសញ្ញានេះ (មាត្រា ២) ។

កិច្ចព្រមព្រៀងបញ្ជាក់ថា កិច្ចប្រាស្រ័យទាក់ទងការទូតបានត្រូវស្ថាបនាឡើង ហើយទំនាក់ទំនងរវាងប្រទេសបារាំង

និងប្រទេសសៀម ក៏ត្រូវមានជាថ្មីឡើងវិញ តាមសន្ធិសញ្ញាចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៣៧។ កិច្ចព្រមព្រៀងបានបញ្ជាក់ម្យ៉ាងទៀតថា ខាងក្រោយការផ្ទេរទឹកដី ដែលគេប្រគល់ឱ្យក្នុងពេលមុនម្តងហើយ នោះមានគណៈកម្មការបង្រួបបង្រួមមួយបានទទួលភារៈពិនិត្យខាងជាតិពន្ធ ខាងភូមិសាស្ត្រ និងខាងសេដ្ឋកិច្ចនៃគូវិវាទ ដើម្បីសើរើពិនិត្យជាថ្មី ឬបញ្ជាក់បន្ថែមនូវ "ខ" ទាំងឡាយនៃសន្ធិសញ្ញាចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៨៩៣ អនុសញ្ញា ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩០៤ និងសន្ធិសញ្ញាចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩០៧។

***ប្រវត្តិវិវាទតំបន់ព្រះវិហារ***

តាមអនុសញ្ញា ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩០៤ បានបញ្ជាក់ជាថ្មីនូវបន្ទាត់ព្រំប្រទល់រវាងប្រទេសសៀម និងកម្ពុជា ហើយ បានព្រាងបង្កើតគណៈកម្មការចម្រុះទទួលភារៈខាងកំណត់ព្រំប្រទល់ដែននេះ។ សន្ធិសញ្ញាចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩០៧ បានប្រគល់ឱ្យអាណាព្យាបាលបារាំងមកវិញ (កម្ពុជា) នូវទឹកដី ទាំងឡាយ ដែលស្ថិតនៅផ្នែកខាងជើង និងផ្នែកខាងលិចប្រទេស។ ក្នុងតំបន់ព្រះវិហារ បន្ទាត់ព្រំប្រទល់ដែន បានសម្រេចតាមអនុសញ្ញា ឆ្នាំ ១៩០៤។ ដូច្នេះតំបន់នេះបានទៅជាទឹកដីខ្មែររួចទៅហើយ មុនការប្រគល់មកវិញជាថ្មីម្តងទៀត នៅឆ្នាំ ១៩០៧ នោះ។

ដោយអនុលោមតាមអនុសញ្ញាចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩០៤ គណៈកម្មការចម្រុះទាំងឡាយ បានត្រូវគេជ្រើស-តាំងឱ្យមានឡើងវិញ ដើម្បីសម្រេចបន្ទាត់ព្រំប្រទល់ដែនដីឱ្យបានទៀងទាត់។ នៅក្នុងអនុសញ្ញានេះ នៅក្នុង មាត្រា ៣ បានចែងថា ប្រទេសបារាំង និងប្រទេសសៀម ត្រូវតែងតាំងនាយ-ទាហានទាំងឡាយ ដើម្បីឱ្យធ្វើជាសមាជិកនៃគណៈកម្មការខាងលើនេះ ហើយការងារនៃគណៈកម្មការនឹងប្រព្រឹត្តទៅចំពោះព្រំដែន ដែលសម្រេចហើយ។

គណៈកម្មការនេះបានតែងតាំងជាច្រើនឆ្នាំ ហើយបានបើកការប្រជុំជាច្រើនលើក។ នាយទាហានទាំងឡាយខាងភូមិសាស្ត្រ បានបំពេញការងាររបស់គណៈកម្មការ ហើយបានធ្វើការពិនិត្យគ្រប់យ៉ាងដល់ទីកន្លែង។

គណៈកម្មការ ដែលបានរួមប្រជុំដើម្បីអនុវត្តសន្ធិសញ្ញា ឆ្នាំ ១៩០៧ (ពេលប្រជុំចុងក្រោយបង្អស់នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩០៨) បានថ្លែងថា ការបោះបង្គោលបានធ្វើរួចហើយ សម្រាប់ព្រំប្រទល់រវាងឥណ្ឌូចិន និងប្រទេសសៀម។ ចំពោះបង្គោលព្រំប្រទល់ដែនជាស៊ីម៉ងតិ៍ ជាដែក ឬជាឈើ មានតាំងនៅចំណុចធំៗខ្លះនៃព្រំប្រទល់ដែន។ ប៉ុន្តែនៅក្នុងកំណត់ហេតុចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ១៩០៨ មិនបាននិយាយពីការដាំបង្គោលនៅក្នុងតំបន់ព្រះវិហារឡើយ។

ម្យ៉ាងទៀត គណៈកម្មការបានទាំងព្រាងធ្វើផែនទីមួយ ដែលមានព្រំប្រទល់ដែនទាំងអស់ រវាងឥណ្ឌូចិន និងប្រទេសសៀម ដោយប្រើឯកសារការងារខាងធ្វើផែនទី។ ឯកសារខាងធ្វើផែនទីនោះ គឺគេកំណត់ថា ជាផែនទីនៃគណៈកម្មការកំណត់ព្រំប្រទល់ដែនរវាងឥណ្ឌូចិន និងប្រទេសសៀម។

**ផែនទីនេះ បានធ្វើពីរលើក៖**

- ផែនទីលើកទី ១ បានបង្កើតឡើងដោយអនុវត្តតាមអនុសញ្ញាចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩០៤ ក្រោមការដឹកនាំរបស់លោក *លីយ៉ឺតឺណង់ កូឡូណែលប៊ែរណា* (Lieutenant Colonel Bernard)។ ផែនទីនេះ មានព្រំប្រទល់ដែនថ្មីទាំងអស់ពីសមុទ្រទៅទន្លេមេគង្គ ដោយអនុលោមតាមអនុសញ្ញានោះ (១៣-០២-១៩០៤)។

- ផែនទីលើកទី ២ បានត្រូវគណៈបេសកកម្មម៉ុងហ្គ័រ (Mission Monguers) ជាអ្នកស្ថាបនាឡើងតាមសន្ធិសញ្ញាចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩០៧ ហើយនៅក្នុងសន្ធិសញ្ញានេះប្រទេសសៀមបានប្រគល់ឱ្យអាណាព្យាបាលបារាំង នូវទឹកដីសំខាន់ៗជាច្រើន នៅផ្នែកខាងលិចនៃប្រទេសកម្ពុជា។ ផែនទីនេះទៅចប់ត្រឹមជួរភ្នំដងរែក ដែលកំណត់ថ្មី (ឆ្នាំ ១៩០៧) យកតាមព្រំប្រទល់ចាស់ (ឆ្នាំ១៩០៤) រហូតដល់ទន្លេមេគង្គឥតមានកែប្រែអ្វីឡើយ។

អំពីព្រះវិហារ, សន្ធិសញ្ញា ឆ្នាំ ១៩០៧ មិនបានធ្វើសេចក្តីកែប្រែអ្វីឡើយ ចំពោះទីកន្លែងនោះ គឺថា នៅដដែលតាមសេចក្តីសម្រេចនៃអនុសញ្ញាឆ្នាំ ១៩០៤ *បានបង្ហាញភស្តុតាងយ៉ាងច្បាស់ថា តំបន់ព្រះវិហារស្ថិតនៅក្នុងដីខ្មែរ*។ ម្យ៉ាងទៀតនៅក្នុងផែនទីសៀម (១/២០០.០០០) ដែលក្រុមខាងភូមិសាស្ត្រសៀមបានធ្វើ ហើយក៏បញ្ជាក់យ៉ាងច្បាស់នៅសន្លឹកលេខ ៤៤ នៃផែនទីនោះ ស្តីពីព្រំប្រទល់ដែនដងរែកថា *ទីកន្លែងប្រាសាទព្រះវិហារស្ថិតនៅក្នុងដែនដីខ្មែរ*។

ផែនទីសៀមនេះបង្ហាញភស្តុតាងឱ្យឃើញថា រាជការសៀមបានទទួលស្គាល់ជាផ្លូវការថា តំបន់ព្រះវិហារជាតំបន់មានលក្ខណៈជាខ្មែរ។ ផ្នែកទាំងពីរនៃផែនទីបារាំង និងផែនទីសៀមពិតជាមានសភាពមិនស្របគ្នាទេ ប៉ុន្តែបង្ហាញឱ្យឃើញថា មានការប្រហាក់ប្រហែលគ្នា ព្រោះព្រះវិហារបានកំណត់យ៉ាងច្បាស់ក្នុងផែនទីទាំងពីរនោះ។ ព្រំប្រទល់ដែននៅខាងជើងដាច់ណាត់ពីប្រាសាទព្រះវិហារ ចម្ងាយ ៥០០ ម៉ែត្រ។ ការប្រហែលគ្នានៃឯកសារទាំងពីរនេះ បញ្ជាក់ឱ្យឃើញយ៉ាងពិតប្រាកដថា គូភាគីទាំងពីរ បានព្រមព្រៀងជាមួយគ្នាទុកព្រះវិហារឱ្យស្ថិតនៅក្នុងដែនដីខ្មែរ។ នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៥៤ រដ្ឋាភិបាលសៀម

បានឆ្លើយតបចំពោះតំណាងរាស្ត្រ ដែលសួរថា : *តើការដែលប្រទេសសៀមទទួលស្គាល់ប្រទេសកម្ពុជា តម្រូវឱ្យថៃយល់ព្រមកាត់កាប់នូវសិទ្ធិរបស់ខ្លួនលើខេត្តទាំងឡាយ ដែលប្រគល់ឱ្យជាថ្មីម្ដងទៀតនៅឆ្នាំ ១៩៤៧ ឬ?*

ព្រះអង្គម្ចាស់ *នរាធិប* រដ្ឋមន្ត្រីក្រសួងការបរទេសសៀម បានមានបន្ទូលថា ទ្រង់គិតដល់តម្លៃឯករាជ្យនៃប្រទេសកម្ពុជា ជាងការបានខេត្តទាំងឡាយ ដែលត្រូវប្រគល់ឱ្យកម្ពុជាវិញនៅឆ្នាំ ១៩៤៦ ទៅទៀត ។ ទ្រង់មានបន្ទូលទៀតថា រដ្ឋាភិបាលសៀមមិនត្រូវប្រព្រឹត្តិនយោបាយពង្រីកដែនដីទេ ហើយប្រទេសសៀមមានសេចក្ដីពេញចិត្ត ដោយឃើញមានការកែតម្រូវព្រំដែនខ្លះ ដែលមានប្រយោជន៍តិចតួចដូចជា បញ្ហាភ្នំប្រាសាទព្រះវិហារ ។ រដ្ឋាភិបាលសៀមពេញចិត្តតាមចំណុចនោះ ក្នុងកិច្ចចរចាសម្រុះសម្រួលគ្នាជាមួយប្រទេសកម្ពុជា ដោយអនុលោមតាមច្បាប់អន្តរជាតិ។ ត្រង់នេះប្រាកដថា ប្រទេសសៀម ពិតជាទទួលស្គាល់ព្រះវិហារជារបស់ខ្មែរ ។

ពីរ បីខែក្រោយមក នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៥៥ សេនាប្រមុខ *ភីន គុនហាវ៉េ* ជារដ្ឋមន្ត្រីថៃទី ១ ស្ដីទី ក្នុងសេចក្ដីប្រកាសចំពោះទីភ្នាក់ងារសារព័ត៌មានបារាំង បានប្រកាសអំពីរឿងព្រំប្រទល់ដែនថា រដ្ឋាភិបាលសៀមមានបំណងចាត់តាំងគណៈកម្មការមួយ ដើម្បីកំណត់ព្រំប្រទល់ដែនរវាងប្រទេសសៀម និងប្រទេសកម្ពុជា ហើយថា ជាពិសេស គួរគប្បីដោះស្រាយបញ្ហាភ្នំព្រះវិហារ ។ ត្រង់នេះទៀត គឺជាការទទួលស្គាល់ថា ព្រះវិហារជារបស់ខ្មែរ ។

នៅក្នុងសៀវភៅមួយលក្ខណៈជាផ្លូវការ ដែលមានចំណងជើងថា *"ថៃសម័យសាងឆាត"* បោះពុម្ពផ្សាយឆ្នាំ ១៩៤១ មាននិយាយពីអនុសញ្ញាក្រុងតូក្យូ ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ១៩៤១ បានប្រគល់ឱ្យសៀមនូវអតីតដែនដីឥណ្ឌូចិនបារាំងមួយចំណែកខាងប្រទេសលាវ (ប្រាសាទវត្តភូ) និងប្រទេសកម្ពុជា (ប្រាសាទព្រះវិហារ) បានចូលមកជារបស់ប្រទេសសៀម បន្ទាប់ពីមានការកែប្រែព្រំប្រទល់ដែននៃអនុសញ្ញានេះ ។ ត្រង់ចំណុចនេះ គឺទទួលស្គាល់ថា ព្រះវិហារមុនឆ្នាំ ១៩៤១ ជារបស់ខ្មែរ ។

### ដើមកំណើតនៃវិវាទរវាងប្រទេសកម្ពុជា និងប្រទេសថៃ

ទោះបីមានបទបញ្ញត្តិយ៉ាងច្បាស់នៃសន្ធិសញ្ញាទាំងឡាយ និងមានការបំភ្លឺពីឯកសារខាងផែនទី ដែលធ្វើឡើងដោយអនុវត្តតាមសន្ធិសញ្ញាទាំងនោះ និងសេចក្ដីប្រកាសជាផ្លូវការខ្លះនៃរដ្ឋាភិបាលថៃក្ដី ក៏ប្រទេសសៀមនៅមិនព្រមឈប់ធ្វើបាតុកម្ម ដោយសញ្ញាផ្សេងៗថា ខ្លួននៅតែយកចិត្តទុកដាក់ប្រាសាទព្រះវិហារជាប្រាសាទតាំងនៅក្នុងដែនដីសៀមដដែល ។

មុនឯករាជ្យប្រទេសកម្ពុជា ស្ថានឯកអគ្គរដ្ឋទូតនៃប្រទេសបារាំងប្រចាំក្រុងបាងកក បានតវ៉ាជាច្រើនលើកប្រឆាំងនឹងការប្រព្រឹត្តរបស់រាជការសៀម ៖

- លិខិតកត់ហេតុលេខ ២៩/៤៩/C ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៤៩ តវ៉ាប្រឆាំងនឹងហេតុថា រាជការប្រទេសថៃបានបញ្ជូនឆ្មាំម្នាក់ និងគូលី ៣ នាក់ឱ្យទៅកាប់ឆ្ការព្រៃចេញពីប្រាសាទព្រះវិហារ ។ គឺលិខិតកត់ហេតុប្រឆាំងនឹងការឈ្លានពានទឹកដីខុសច្បាប់នេះហើយ ដែលបញ្ជាក់ថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងដែនដីខ្មែរ ។

- លិខិតកំណត់ហេតុលេខ ៦៩/៤៩/C ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៤៩ បញ្ជាក់បន្ថែមលើសេចក្ដីតវ៉ាលើកមុន ហើយសុំចំពោះរដ្ឋមន្ត្រីសៀមខាងក្រសួងការបរទេសឱ្យបំបាត់កុំឱ្យមានស្ថានការណ៍ប្រកបដោយភាពសង្ស័យ ដែលបណ្ដាលមកពីការប្រព្រឹត្តិរបស់រាជរដ្ឋាភិបាលសៀម ហើយសុំឱ្យបន្ថយឆ្មាំជនជាតិសៀមទាំងឡាយ ដែលតាំងនៅក្បែរប្រាសាទព្រះវិហារនោះចេញ ។

- នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៤៩ តាមលិខិតលេខ ១៩៧ លោក *ឡេអុងម៉ារសាល់ (Leong Marsall)* ជាឯកអគ្គរដ្ឋទូតនៃប្រទេសបារាំង ប្រចាំបាងកក បានជូនដំណឹងដល់ស្នងការជាន់ខ្ពស់នៃប្រទេសបារាំងប្រចាំឥណ្ឌូចិនថា ភ្នាក់ងាររាជការម្នាក់របស់លោក នៅស្ថានឯកអគ្គរដ្ឋទូតប្រចាំបាងកក បានបង្ហាញផែនទីកំណត់ព្រំប្រទល់ដែន ១/២០០.០០០ ចំពោះអគ្គនាយកនៃមន្ទីរខាងទិសបូព៌ា នៅមន្ទីររដ្ឋមន្ត្រីក្រសួងការបរទេសសៀម ។ ភ្នាក់ងាររាជការសៀមនេះ បានទទួលស្គាល់ទុកការតវ៉ាទាមទារនៃប្រទេសកម្ពុជា ថាមានសភាពត្រឹមត្រូវ ។

- លិខិតកត់ហេតុលេខ ១១៨០ ចុះថ្ងៃទី ៣ កក្កដា ឆ្នាំ ១៩៥០ នៃស្ថានឯកអគ្គរដ្ឋទូតប្រទេសបារាំង ប្រចាំក្រុងបាងកក បានផ្ញើជូនទៅរដ្ឋាភិបាលសៀម ដើម្បីរំលឹកអំពីលិខិត ដែលខ្លួនបានផ្ញើទៅពេលមុន ។

ក្រោយប្រទេសខ្មែរ ទទួលឯករាជ្យ លិខិតទាំងឡាយអំពីរឿងប្រាសាទព្រះវិហារ ត្រូវបានប្ដូរគ្នាទៅវិញទៅមកជាថ្មីរវាងស្ថានឯកអគ្គរាជទូតខ្មែរ ដែលទើបនឹងតាំងថ្មីនាក្រុងបាងកក នឹងរដ្ឋបាលថៃ ។ លទ្ធផលជាវិជ្ជមានឥតបានកើតមានបន្តិចបន្តួចសោះឡើយ ។

ការប្រព្រឹត្តិនៃរាជការប្រទេសសៀម នៅតែដដែល រដ្ឋាភិបាលខ្មែរក៏ត្រូវតែធ្វើសេចក្ដីតវ៉ាដូចគ្នា និងសេចក្ដីតវ៉ា ដែលអ្នកតំណាងទាំងឡាយនៃរដ្ឋាភិបាលបារាំង បានផ្ញើជូនទៅរដ្ឋាភិបាលសៀមនោះដែរ ។

- លិខិតលេខ ១៤ DGP-X ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៥៤ ឯកអគ្គរាជទូតនៃប្រទេសកម្ពុជាប្រចាំក្រុងបាងកក បានតវ៉ាចំពោះរដ្ឋមន្ត្រីក្រសួងការបរទេសសៀម ប្រឆាំងនឹងសេចក្ដី

បង្គាប់ ដែលរាជការឱ្យគូលីខ្មែរ ៣ នាក់ ដែលរាជការខ្មែរបានជ្រើសយកមកឱ្យនៅថែរក្សាប្រាសាទនោះ ឱ្យឈប់បំពេញមុខងាររបស់ខ្លួន និងឱ្យថយចេញពីទីនោះ ។

- នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៥៤ ឯកអគ្គរាជទូតនៃប្រទេសកម្ពុជាបានជួបអនុរដ្ឋលេខាធិការ នៅក្រសួងការបរទេសសៀម ហើយអនុរដ្ឋលេខាធិការរូបនោះ បានប្រាប់ថា បញ្ហាព្រះវិហារ តម្រូវឱ្យរដ្ឋាភិបាលរបស់លោកពិនិត្យដោយហ្មត់ចត់ ហើយថា លោកមុខជានឹងធ្វើជូនឱ្យត្រឹមត្រូវតាមពាក្យសុំនៃរដ្ឋាភិបាលខ្មែរ ។ ប៉ុន្តែ រាជការសៀមនៅតែឱ្យទាហានសៀមមើលថែប្រាសាទព្រះវិហារដដែល ។

- នៅថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ១៩៥៤ លោកអគ្គរាជទូតខ្មែរប្រចាំក្រុងបាងកក បានផ្ញើលិខិតថ្មីមួយច្បាប់ទៅមន្ទីររដ្ឋមន្ត្រីក្រសួងការបរទេសសៀម សុំឱ្យអន្តរាគមន៍ចំពោះរាជការមានសមត្ថកិច្ចនៃប្រទេសរបស់ខ្លួន ដើម្បីឱ្យទាហានថយចេញពីតំបន់ព្រះវិហារដែលខ្លួនបានកាន់កាប់នោះ ។ ទោះបីជាមានការគិតគូរជាញឹកញាប់ពីរដ្ឋាភិបាលខ្មែរយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលសៀមនៅតែរឹងទទឹងរក្សាទុកនូវទាហានទាំងឡាយ ឱ្យថែរក្សាប្រាសាទព្រះវិហារ ដែលជារបស់ខ្មែរ ។

- នៅខែ មករា ឆ្នាំ ១៩៥៥ រាជការសៀមបានយកផ្ទាំងមួយចារឹកជាអក្សរខ្មែរ និងអក្សរសៀម ទៅបោះនៅប្រាសាទព្រះវិហារ ដោយហាមឃាត់ជនបរទេសទាំងអស់ មិនឱ្យត្រាច់ចរទៅតាមប្រាសាទ ។

- នៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៥៥ មានឆ្មាំម្នាក់ជនជាតិសៀមបានចុះបញ្ជីមួយ ដើម្បីជាប្រយោជន៍រាជការសៀមនូវគុណសម្បត្តិ និងអាសយដ្ឋាននៃអ្នកទស្សនាចរ ។

ទោះបីមានការតវ៉ាពីរដ្ឋាភិបាលខ្មែរ និងពីអ្នកតំណាងរបស់ខ្លួនប្រចាំក្រុងបាងកកក៏ដោយ ក៏រាជការសៀមនៅតែប្រកាន់អាកប្បកិរិយារបស់ខ្លួនដដែល ដូចជា ឱ្យកងល្បាតនៃតម្រួតទៅត្រួតពិនិត្យប្រាសាទនោះជាអចិន្ត្រៃយ៍ ។ ជួនបង្ហូតទង់ជាតិសៀម ដែលបក់រវិចៗ នៅខាងមុខប្រាសាទនៅត្រង់មាត់ខ្លង់រាបផ្ទៃកខាងខ្មែរ ជួនកាលទម្លាក់ចុះមកវិញតាមចិត្តដែលខ្លួនចង់ ។ ក្រុមតម្រួតសៀមមួយកង ដែលតាំងនៅចម្ងាយប្រហែល ២០០ ម៉ែត្រ ខាងជើងច្រកចូលនៅក្នុងទឹកដីសៀម បានបញ្ជូនពួកយាមល្បាតឱ្យទៅកាន់ប្រាសាទ ។ នៅតាមផ្លូវលំមកពីភូមិឫស្សី ចម្ងាយ ៥០០ ម៉ែត្រខាងមុខទ្វារចូលទៅក្នុងប្រាសាទ មានចារឹកជាអក្សរសៀម លាបថ្នាំសនៅត្រង់ស្នាប់ជើងនៃសសរ ឬ នៅត្រង់ត្រនាប់ជើងរូប ។ ខ្មែរដែលចង់ទៅហួសប្រាសាទនេះ ត្រូវសុំសេចក្ដីអនុញ្ញាតពីតម្រួតសៀម ។

- នៅខែ កញ្ញា ឆ្នាំ ១៩៥៦ រាជការប្រទេសសៀម បានតម្រូវឱ្យអ្នកស្រុកខ្មែរ ដែលនៅជិតនោះ (ភូមិឫស្សី) ធ្វើជាគូលីជួសជុសថ្នល់ ដែលមកពីណាមឱម (Nam Om) ក្នុងទឹកដីសៀម ។

តាមពិតរដ្ឋាភិបាលខ្មែរ ក៏បានគិតឱ្យមនុស្សទៅកាន់កាប់តំបន់ព្រះវិហារដែរ ដើម្បីបង្ហាញឱ្យឃើញពីសិទ្ធិពិតប្រាកដរបស់ខ្លួន ដែលមានបន្តពីអាណាព្យាបាលបារាំង ។ ម្យ៉ាងទៀត ក្រោយពីឯករាជ្យ រដ្ឋាភិបាលខ្មែរក៏បានចាត់ចែងរឿងនេះភ្លាមដែរ ប៉ុន្តែដោយសារមានការលំបាកនឹងចូលទៅដល់តំបន់នោះ រដ្ឋាភិបាលខ្មែរក៏ឈប់សិន ។ ក្រោយមក ដោយអាកប្បកិរិយានៃរាជការសៀមបានធ្វើឱ្យរំជើបរំជួល រដ្ឋាភិបាលខ្មែរក៏គិតថានឹងទៅកាន់កាប់តំបន់នោះជាថ្មីម្ដងទៀត តែមិនទាន់ទៅកាន់កាប់ផង សៀមបានទៅកាន់កាប់តំបន់ព្រះវិហារមុនទៅហើយ ។ ដើម្បីជៀសវាងការប្រឈមមុខដាក់គ្នា ដែលធ្វើឱ្យខូចទំនាក់ទំនងរវាងប្រទេសទាំងពីរ បានធ្វើឱ្យរដ្ឋាភិបាលខ្មែរមិនបានប៉ុនប៉ងទៅកាន់កាប់ព្រះវិហារវិញ ហើយពេញចិត្តយករឿងនេះដាក់តុចរចាទ្វេភាគីវិញ បើមិនបានសម្រេចដូចសេចក្ដីប្រាថ្នានឹងត្រូវធ្វើពាក្យបណ្ដឹងទៅតុលាការអន្តរជាតិ ។

សរុបសេចក្ដីមកវិវាទរវាងប្រទេសខ្មែរ និងប្រទេសសៀម ក៏ បានឈានទៅដល់ការប្ដឹងទៅតុលាការយុត្តិធម៌អន្តរជាតិ ទីក្រុងឡាអេ ប្រទេសហូល្លង់ដ៍ ។

### ***រឿងក្ដីប្រាសាទព្រះវិហារ***

សៀម បានចូលកាន់កាប់ប្រាសាទព្រះវិហារដោយខុសច្បាប់តាំងពីឆ្នាំ ១៩៤០ និងដាក់បញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីប្រាសាទជាតិសៀម ក្នុងឆ្នាំ ១៩៤០ នោះដែរ បន្ទាប់មក សៀមបានដាក់ឆ្មាំការពារនៅឆ្នាំ ១៩៤១ ។

- កិច្ចព្រមព្រៀងក្រុងវ៉ាស៊ីនតោនចុះថ្ងៃទី ១៧ ឧសភា ឆ្នាំ ១៩៤៦ បានចាត់ទុកអនុសញ្ញា ឆ្នាំ ១៩៤១ ជាមោឃៈ និងតម្រូវឱ្យរក្សាស្ថានភាពព្រំដែន ដូចឆ្នាំ១៩៤១ ។ ប្រទេសសៀមបានប្រគល់ប្រាសាទវត្តភូឱ្យទៅប្រទេសលាវវិញ ប៉ុន្តែសៀមមិនព្រមប្រគល់ប្រាសាទព្រះវិហារ មកឱ្យកម្ពុជាវិញឡើយ ។

- ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៥៣ រដ្ឋាភិបាលខ្មែរ បានប្រើអធិបតេយ្យភាពរបស់ខ្លួន ដែលទើបទាមទារបានមកនោះ ដោយចាត់តាំងជនជាតិខ្មែរ ៣ នាក់ ឱ្យទៅថែរក្សាប្រាសាទព្រះវិហារ ។ ប៉ុន្តែជនជាតិខ្មែរទាំងបីនាក់នោះ ត្រូវចាកចេញពីប្រាសាទមកវិញ តាមបញ្ជាដាច់ណាត់របស់អាជ្ញាធរសៀម ។

- នៅចុងខែ មីនា ឆ្នាំ ១៩៥៤ ដោយមានកង្វល់ក្នុងការស្ដាបនាឡើងវិញ នូវសណ្ដាប់ធ្នាប់ព្រំដែនខាងជើងនោះ រាជរដ្ឋាភិបាលកម្ពុជា បានព្រមានរដ្ឋាភិបាលក្រុងបាងកកថា នឹងបញ្ជូនយុវជនកម្ពុជាទៅកាន់ប្រាសាទព្រះវិហារ ដើម្បីជំនួសឆ្មាំកម្ពុជាដែលដកខ្លួនថយពីប្រាសាទពីពេលមុននោះ ។ ប៉ុន្តែ មុនពេល

អនុវត្តគម្រោងនេះ កងកម្លាំងប្រដាប់អាវុធសៀមបានទៅកាន់កាប់ប្រាសាទនេះដោយខុសច្បាប់រួចទៅហើយ ។

- នៅខែមិថុនា ក្រោយទស្សនកិច្ចជាផ្លូវការ មកកាន់ប្រទេសកម្ពុជារបស់លោក *ថាណាត់ ខូម៉ាន់* រដ្ឋមន្ត្រីការបរទេសសៀមនោះមក កម្ពុជាបានដាក់សំណើជាថ្មីសម្រាប់ឱ្យសៀមជ្រើសរើស គឺការគ្រប់គ្រងប្រាសាទព្រះវិហាររួមគ្នា ដោយប្រទេសកម្ពុជា រក្សានូវអធិបតេយ្យភាពរបស់ខ្លួន ។ បើមិនព្រមនឹងសំណើនេះទេ កម្ពុជានឹងប្តឹងទៅតុលាការអន្តរជាតិ ទីក្រុងឡាអេ ។

- នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៥៩ ខ្មែរបានដាក់បណ្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ ក្រុងឡាអេ ។

- **សវនាការសាធារណៈនៃតុលាការយុត្តិធម៌អន្តរជាតិ ក្រុងឡាអេ ឆ្នាំ ១៩៦១ និង ឆ្នាំ ១៩៦២**

***ភ្នាក់ងាររាជរដ្ឋាភិបាលកម្ពុជា :***

ឯកឧត្តម *ទ្រឿង កាង* សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្គ

***មេធាវីរបស់កម្ពុជា :***

- លោក *ឌិន អាចេហ្សាន់ (Dean Acheson)* សមាជិកស្នាក្តីនៃតុលាការកំពូលសហរដ្ឋអាមេរិក

- លោក *រ៉ូហ្សេ ពិនតូ (Roger Pinto)* សាស្ត្រាចារ្យមហាវិទ្យាល័យនីតិសាស្ត្រ ក្រុងប៉ារីស

- លោក *ប៉ូល រើទែរ (Paul Reuter)* សាស្ត្រាចារ្យមហាវិទ្យាល័យនីតិសាស្ត្រ ក្រុងប៉ារីស

***សាក្សី :***

លោក *សួន បុន* អភិបាលខេត្តកំពង់ធំ ពីឆ្នាំ ១៩៤៨ ដល់ឆ្នាំ ១៩៥៤ ។

- **សេចក្តីថ្លែងការណ៍របស់ឯកឧត្តម *ទ្រឿង កាង* ក្នុងសវនាការនៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៦២**

*លោកប្រធាន អស់លោកចៅក្រម*

*សេចក្តីសន្និដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា មានដូចតទៅ :*

*សូមតុលាការមេត្តា :*

១- និយាយ និងវិនិច្ឆ័យថា ខ្សែបន្ទាត់ព្រំដែនរវាងប្រទេសកម្ពុជា និងថៃ នៅក្នុងតំបន់ភ្នំដងរែក គឺខ្សែបន្ទាត់ ដែលបានគូសនៅលើផែនទី របស់គណៈកម្មការកំណត់ព្រំដែនរវាងឥណ្ឌូចិន និងសៀម ។

២- និយាយ និងវិនិច្ឆ័យថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីជាអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា ។

៣- និយាយ និងវិនិច្ឆ័យថា ព្រះរាជាណាចក្រថៃនឹងត្រូវដកទាហាន ដែលបោះទីតាំងនៅក្នុងទឹកដីកម្ពុជាតាំងពី ឆ្នាំ ១៩៥៤ នោះចេញពីប្រាសាទព្រះវិហារវិញ ។

៤- និយាយ និងវិនិច្ឆ័យថា រូបចម្លាក់ សិលាចារឹក ថ្មប្រាសាទ និងវត្ថុផ្សេងៗទៀត ដែលអាជ្ញាធរថៃបានយកចេញពីប្រាសាទព្រះវិហារ តាំងពីឆ្នាំ ១៩៥៤ នោះ រដ្ឋាភិបាលថៃត្រូវប្រគល់មកឱ្យកម្ពុជាវិញ ។

- **សាលក្រមតុលាការយុត្តិធម៌អន្តរជាតិឆ្នាំ ១៩៦២**

សំណុំរឿងប្រាសាទព្រះវិហារ តាមសាលក្រមតុលាការក្រុងឡាអេ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៦២ គឺ បានសម្រេច :

*ដោយមានសម្លេង ៩ ទល់នឹង ៣* តុលាការបានសម្រេចថា ប្រាសាទព្រះវិហារស្ថិតក្នុងទឹកដីនៅក្រោមអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ហើយដោយហេតុនេះ ប្រទេសថៃត្រូវដកកងកម្លាំងប្រដាប់អាវុធទាំងអស់ ឬកងប៉ូលីស ឬអ្នកយាម និងឆ្មាំ ដែលប្រទេសនេះបានដាក់នៅក្នុងប្រាសាទនេះឬក៏នៅជុំវិញប្រាសាទ ដែលស្ថិតនៅក្នុងទឹកដីរបស់ប្រទេសកម្ពុជា ។

*ដោយសម្លេង ៧ ទល់នឹង ៥* តុលាការបានសម្រេចថា ប្រទេសថៃត្រូវតែប្រគល់មកឱ្យប្រទេសកម្ពុជាវិញ នូវរូបចម្លាក់ សិលាចារឹក បំណែកនៃបូជនីយដ្ឋាន រូបសំណាកធ្វើអំពីថ្មភក់ និងគ្រឿងចានឆ្នាំងធ្វើអំពីដីនានា ដែលចាប់តាំងពីពេលប្រាសាទនេះត្រូវបានកាន់កាប់ដោយប្រទេសថៃ ពីឆ្នាំ ១៩៥៤ មក អាចនឹងត្រូវក្រសួងមានសមត្ថកិច្ចរបស់ប្រទេសនេះ យកចេញពីប្រាសាទនេះ ឬមួយយកពីក្នុងតំបន់ប្រាសាទនេះទៅ ។

ដំបូងប្រទេសសៀម បានបដិសេធចំពោះសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិ ក្រុងឡាអេ ។ ប៉ុន្តែនៅទីបំផុត គឺនៅថ្ងៃទី **២១ ខែ មិថុនា ឆ្នាំ ១៩៦២** លោកសេនាប្រមុខ *សារិត (Sarit)* ថ្លែងថា ប្រទេសរបស់លោក សូមលំឱនកាយទទួលយកសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ ដើម្បីគោរពតាមកិច្ចសន្យារបស់ខ្លួន ចំពោះធម្មនុញ្ញសហប្រជាជាតិ ។

នៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៦៣ សម្តេច *ព្រះនរោត្តម សីហនុ* ជាព្រះប្រមុខរដ្ឋ ដែលអមព្រះរាជដំណើរដោយព្រះសង្ឃ និងឥស្សរជនខ្មែរជាច្រើនរូបបានយាង និមន្ត និងអញ្ជើញឡើងកាន់កាប់ប្រាសាទព្រះវិហារពីពេលនោះមក ។

***កាលបរិច្ឆេទសំខាន់ៗ ដែលទាក់ទងនឹងការស្នើសុំចុះបញ្ជីប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភពលោក***

រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាសេនាធិការ បានរៀបចំឯកសារ តាំងពីឆ្នាំ ២០០១ មកម្ល៉េះ ដើម្បីដាក់បញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក ។ ប៉ុន្តែ ដោយមានកំហុសឯកសារ ទើបយឺតយ៉ាវ

ព្រោះយកឯកសារចាស់ មកកែធ្វើជាថ្មី ហើយត្រូវសរសេរឡើងវិញ។ ឯកសារនេះ ត្រូវរៀបចំឱ្យចប់មុនឆ្នាំ ២០០៦ ហើយនៅខែ មករា ឆ្នាំ ២០០៦ ត្រូវយកមកពិនិត្យមើលឡើងវិញ ប្រសិនបើ មិនខុសឆ្គងទេ មួយឆ្នាំក្រោយមក (ឆ្នាំ២០០៧) ត្រូវប្រកាសបញ្ចូលជាផ្លូវការទៅជាបេតិកភណ្ឌពិភពលោក។[៣]

ខាងក្រោមនេះជាកាលបរិច្ឆេទសំខាន់ៗក្នុងការស្នើសុំចុះបញ្ជីប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភពលោក÷

- ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០១ : បានចាប់ផ្ដើមរៀបចំឯកសារស្នើសុំចុះបញ្ជីប្រាសាទព្រះវិហារ ចូលជាបេតិកភណ្ឌពិភពលោក។

- ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៥ : អគ្គនាយកអង្គការយូណេស្កូ លោក *កូអ៊ីជីរ៉ូ ម៉ាត់ស៊ូអ៊ូរ៉ា* បានមានប្រសាសន៍ថា អង្គការរបស់លោក បានបញ្ជូនក្រុមអ្នកឯកទេសទៅកាន់ប្រាសាទព្រះវិហារហើយ ដើម្បីពិនិត្យ និងរៀបចំដាក់ប្រាសាទ ដែលនៅជាប់ព្រំដែនសៀមនេះ ឱ្យទៅជាបេតិកភណ្ឌពិភពលោក។

- ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៦ : ដាក់ពាក្យស្នើសុំចុះបញ្ជីប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភព ជូនគណៈកម្មការបេតិកភណ្ឌពិភពលោក នៅទីក្រុងប៉ារីស បន្ទាប់ពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយមានទីប្រឹក្សាបច្ចេកទេស និងជំនួយដ៏សកម្មពីសំណាក់អង្គការយូណេស្កូប្រចាំកម្ពុជា បានរៀបចំឯកសារពេញលេញមួយ ស្របតាមទិសដៅណែនាំការអនុវត្តអនុសញ្ញាស្ដីពីការការពារបេតិកភណ្ឌវប្បធម៌ និងធម្មជាតិពិភពលោក (ឆ្នាំ ១៩៧២)។

- ថ្ងៃទី ២៣-២៩ ខែតុលា ឆ្នាំ ២០០៦ : បេសកកម្មបច្ចេកទេសរបស់ក្រុមប្រឹក្សាអន្តរជាតិ ស្ដីពីប្រាង្គប្រាសាទ និងរមណីយដ្ឋាន (ICOMOS) មកកាន់ប្រាសាទព្រះវិហារ។

- ថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០០៧ : កម្ពុជាបានផ្ញើជូននូវព័ត៌មានបន្ថែម ស្ដីពីរមណីយដ្ឋានប្រាសាទព្រះវិហារ។ ក្រុមប្រឹក្សាអន្តរជាតិ ស្ដីពីប្រាង្គប្រាសាទ និងរមណីយដ្ឋាន បានទទួលស្គាល់តម្លៃសាកលដ៏អស្ចារ្យនៃរមណីយដ្ឋាន ហើយបានផ្ដល់អនុសាសន៍ឱ្យដាក់រមណីយដ្ឋានជាទីសក្ការៈនៃប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភពលោក។

- ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៧ : រាជរដ្ឋាភិបាលកម្ពុជាបានស្វែងរកការគាំទ្រពីបណ្ដាប្រទេសជាមិត្ត ដោយមានរៀបចំកិច្ចប្រជុំមួយនៅទីស្ដីការក្រសួងការបរទេស រវាងឯកឧត្តម *ហោ ណាំហុង* និងឯកឧត្តម *សុខ អាន* ជាមួយឯកអគ្គរដ្ឋទូតនៃបណ្ដាប្រទេសជាមិត្តប្រចាំនៅកម្ពុជា រួមមាន កាណាដា កូរ៉េខាងត្បូង ជប៉ុន ឥណ្ឌា និងគុយបា។

- ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ : ឯកឧត្តម *សុខ អាន* ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី បានដឹកនាំគណៈប្រតិភូកម្ពុជា ចាកចេញពីទីក្រុងភ្នំពេញ ដើម្បីទៅចូលរួមប្រជុំរបស់អង្គការយូណេស្កូ ដែលប្រព្រឹត្តទៅនៅប្រទេសនូវែលហ្សេឡង់។

- ថ្ងៃទី ២៣ ខែ មិថុនា ដល់ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៧ : គណៈកម្មការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូក្នុងសម័យប្រជុំលើកទី ៣១ នៅទីក្រុងគ្រែឆឺច ប្រទេសនូវែលហ្សេឡង់ បានពិនិត្យសំណុំឯកសារទាំងអស់ពាក់ព័ន្ធនឹងសំណើនេះ រួចទទួលស្គាល់ថា រមណីយដ្ឋានជាទីសក្ការៈនៃប្រាសាទព្រះវិហារមានសារសំខាន់ជាអន្តរជាតិ ហើយមានតម្លៃសាកលអស្ចារ្យ ព្រមទាំងសម្ដែងនូវសេចក្ដីយល់ព្រមជាគោលការណ៍ចំពោះការដាក់ប្រាសាទព្រះវិហារ ជាបេតិកភណ្ឌពិភពលោក ហើយប្រធានគណៈកម្មាធិការនេះបានថ្លែងថា សេក្ដីសម្រេចនេះមានន័យថា គណៈកម្មាធិការបានយល់ព្រមថា រមណីយដ្ឋានជាទីសក្ការៈនេះ ស័ក្ដិសមនឹងបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ហើយការបញ្ចូលនឹងធ្វើនៅការប្រជុំលើកទី ៣២ នាឆ្នាំ ២០០៨។[៤]

- ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០០៧ ក្រសួងការបរទេសសៀមបានកោះប្រជុំទីភ្នាក់ងាររដ្ឋាភិបាលទាំងអស់ ដែលពាក់ព័ន្ធចំពោះក្រុមការងារពិសេស ទទួលបន្ទុកការដាក់បញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៃអង្គការយូណេស្កូ។ យោងទៅតាមសេចក្ដីប្រកាសព័ត៌មាន ដែលចេញដោយក្រសួងការបរទេសសៀម បានឱ្យដឹងថា លោកឯកអគ្គរាជទូត *ម៉ាណាស ប៉ាសស៊ូតូ (Manas Pasxuto)* ដែលជាបេសកជន ពិសេសរបស់ក្រសួងការបរទេសសៀម និងជាអ្នកដឹកនាំគណៈប្រតិភូសៀមទៅចូលរួមប្រជុំលើកទី ៣១ នៅទីក្រុងគ្រែឆឺច (Christchurch) នៃប្រទេសនូវែលហ្សេឡង់នោះ បានអះអាងថា ប្រទេសសៀម បានគាំទ្រជានិច្ចដល់ការដាក់បញ្ចូលប្រាសាទព្រះវិហារ ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ហើយបានស្នើឱ្យទីភ្នាក់ងាររដ្ឋាភិបាលទាំងអស់ ត្រៀមខ្លួនជាស្រេចសម្រាប់កិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ដើម្បីសម្របសម្រួលដំណើរការនេះ។

---

[៣] ប្រសាសន៍របស់ឯកឧត្តម ជុច ភឿន, កាសែតកោះសន្តិភាព ចេញផ្សាយថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៥

[៤] សារសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ផ្ញើជូនចំពោះជូនជនរួមជាតិ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨។

- ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៧ : លោក *Joseph Mussomeli* ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំកម្ពុជា បានមានប្រសាសន៍ថា ស្ថានទូតសហរដ្ឋអាមេរិកគាំទ្រជាផ្លូវការ ការចុះបញ្ជីប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក នៅក្នុងជំនួបជាមួយឯកឧត្តម *សុខ អាន* ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។

- ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ : ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី *សុខ អាន* នៅទីស្ដីការគណៈរដ្ឋមន្ត្រី ក្នុងជំនួបនៃការជម្រាបលារបស់លោកស្រី *ដូនីកា ប៉ូទី* ( Donica Pottie ) បានមានប្រសាសន៍ថា យើងបានប្រជែងយ៉ាងខ្លាំងជាមួយប្រទេសសៀម លើបញ្ហាចំនួន ៣ ដែលក្នុងនោះ មានបញ្ហាព្រំដែន ដែលចំណុចនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានលើកការសម្រេចរបស់តុលាការអន្តរជាតិ ទីក្រុងឡាអេ ឆ្នាំ ១៩៦២ ដែលពុំអាចកែប្រែបានឡើយ។ ចំណុចទី ២ ភាគីសៀម បានស្នើឱ្យមានការពិភាក្សាគ្នា ចំពោះការដាក់ប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ចំណុចនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានលើកឡើងថា ប្រទេសកម្ពុជា ជាប្រទេសមានអធិបតេយ្យភាព ដូច្នេះ មិនចាំបាច់មានការពិភាក្សានោះទេ ព្រោះប្រាសាទព្រះវិហារជារបស់ខ្មែរ។ ចំណុចទី ៣ ភាគីសៀម បានលើកឡើងពីសកម្មភាពរបស់យោធា នៅប្រាសាទព្រះវិហារ បញ្ហានេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានលើកឡើងថា យើងកំពុងនិយាយអំពីបញ្ហាវប្បធម៌ មិនមែននិយាយអំពីបញ្ហាទាហាននោះទេ។ ប្រាសាទព្រះវិហាររបស់កម្ពុជា ត្រូវតែបានប្រកាសដាក់ជាបេតិកភណ្ឌពិភពលោកនៅឆ្នាំក្រោយ នៅទីក្រុងកេបិក ប្រទេសកាណាដា ជាដាច់ខាត។

- ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧ : គណៈប្រតិភូមួយក្រុម រួមមាន ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក តំណាងស្ថានទូតកាណាដា តំណាងស្ថានទូតជប៉ុន និងតំណាងក្រសួងពាក់ព័ន្ធ ដែលដឹកនាំដោយឯកឧត្តម *វ៉ា គឹមហុង* ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា បានចុះទៅពិនិត្យមើលស្ថានភាពជាក់ស្ដែងរបស់ប្រាសាទព្រះវិហារ។

- ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៨ : ឯកឧត្តម *សុខ អាន* ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈ-រដ្ឋមន្ត្រី អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបរបាយការណ៍ស្រាវជ្រាវ និងដើម្បីរៀបចំផែនការជាជំហានក្នុងកិច្ចអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានសក្ការៈព្រះវិហារ។ របាយការណ៍នេះត្រូវដាក់ជូនគណៈកម្មាធិការបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ ដែលជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ជាម្ចាស់ទ្រព្យ ត្រូវបំពេញបន្ត ក្រោយពីរមណីយដ្ឋាននេះត្រូវជាប់ឈ្មោះជាគោលការណ៍ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលបានប្រកាសដោយអង្គការបេតិកភណ្ឌពិភពលោក ក្នុងសម័យប្រជុំពេញអង្គ លើកទី ៣១ ធ្វើនៅទីក្រុងគ្រៃឆឺច ប្រទេសនូវែលហ្សេឡង់ កាលពីដើមខែ កក្កដា ឆ្នាំ ២០០៧។

- ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨ : នៅទីក្រុងភ្នំពេញ បានប្រារព្ធអង្គប្រជុំរបស់គណៈកម្មាធិការជាន់ខ្ពស់សម្រាប់តាមដានសំណុំឯកសារនៃការសុំចុះបញ្ជីរមណីយដ្ឋានប្រាសាទព្រះវិ-ហារជាទីសក្ការៈជាផ្លូវការ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក របស់អង្គការយូណេស្កូ។

- ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៨ ទីស្ដីការគណៈរដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានចេញផ្សាយនូវសេចក្ដីប្រកាសព័ត៌មានដែលទាក់ទងនឹងការប្រជុំ កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨ ខាងលើ។

- ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០៨ : លោក *សាម៉ាក់ ស៊ុនដារ៉ាវេត* នាយករដ្ឋមន្ត្រីសៀម ដែលទើបឡើងកាន់តំណែង បានធ្វើការបញ្ជាក់ជាថ្មីថា រដ្ឋាភិបាលសៀម មិនបានជំទាស់នឹងប្រទេសកម្ពុជា ក្នុងការដាក់បញ្ចូលប្រាសាទព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោកទេ ហើយជំហរផ្លូវការរបស់រដ្ឋាភិបាលសៀមបានប្រកាសអះអាងនៅចំពោះមុខថ្នាក់ដឹកនាំកម្ពុជា។

- ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ លោក *Teruo Jinnai* តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា បានថ្លែងនៅខេត្តបន្ទាយមានជ័យក្នុងទិវាវប្បធម៌ជាតិកម្ពុជាថា "កម្ពុជាបច្ចុប្បន្នកំពុងដំណើរការរៀបចំដាក់បញ្ចូលប្រាសាទព្រះវិហារដ៏ប្រណិតទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ អង្គការយូណេស្កូ បានធ្វើការសហការយ៉ាងជិតស្និទ្ធិជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការចុះបញ្ជីនេះ"។

- ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៨ : កម្ពុជា-សៀម បានចេញសេចក្ដីថ្លែងការណ៍រួមបន្ទាប់ពីកិច្ចប្រជុំ ស្ដីពី ប្រាសាទព្រះវិហារ រវាងគណៈប្រតិភូកម្ពុជាដឹកនាំដោយឯកឧត្តម *សុខ អាន* ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈ-រដ្ឋមន្ត្រី និងគណៈប្រតិភូថៃដឹកនាំដោយឯកឧត្តម *វីរ៉ាសាឌី ហ៊្វូត្រាគល់* អគ្គលេខាធិការនៃក្រសួងការបរទេសថៃ។

- ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨ : ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី *សុខ អាន* បានដឹកនាំគណៈប្រតិភូកម្ពុជាផ្លូវការមួយក្រុម ទៅធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលបេតិភណ្ឌពិភពលោក នាទីក្រុងប៉ារីស ប្រទេសបារាំង ដើម្បីជួបពិភាក្សាគ្នាជាមួយមន្ត្រីអង្គការយូណេស្កូ ទាក់ទងការដាក់ប្រាសាទព្រះវិហាររបស់កម្ពុជាចូលទៅក្នុងសម្បត្តិបេតិកភណ្ឌពិភពលោក ហើយដើម្បីសម្រេបសម្រួលការងារត្រៀមលក្ខណៈឆ្លើយតប និងកិច្ចប្រជុំពេញអង្គលើកទី ៣២ នៅប្រទេសកាណាដា អំពីការត្រៀមឯកសារដាក់

ប្រាសាទព្រះវិហាររបស់កម្ពុជា ចូលទៅក្នុងសម្បត្តិបេតិកភណ្ឌពិភពលោក។

- ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ : ឯកឧត្តម *សុខ អាន* និងឯកឧត្តម *ណុបផាដុន ប៉ាតាម៉ា* រដ្ឋមន្ត្រីការបរទេសសៀម និងលោកជំទាវ *ហ្វ្រង់ស្វ័ហ្ស រីវីយែរ* អគ្គនាយករងនៃអង្គការយូណេស្កូ បានជួបប្រជុំ និងឯកភាពគ្នានៅទីស្នាក់ការយូណេស្កូ ទីក្រុងប៉ារីស។

- ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៨ : ឯកឧត្តម *ប៉ែន ងឿន* ទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី និងជាសេនាធិការទាក់ទិនករណីប្រាសាទព្រះវិហារ បាននិយាយឱ្យដឹងថា គំនូសផែនទីកំណត់បរិវេណប្រាសាទព្រះវិហារ ត្រូវបានបញ្ជូនឱ្យទៅប្រទេសសៀម និងទីក្រុងប៉ារីសរួចហើយ។ គំនូសផែនទីថ្មីនេះត្រូវ បានប្រទេសសៀមយល់ព្រមទទួលស្គាល់ដោយការយោគយល់គ្នា និងទំនាក់ទំនងល្អ។

- ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨ : សម្ដេចអគ្គមហាសេនាបតីតេជោ *ហ៊ុន សែន* នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានស្នើសុំឱ្យតំណាងរាជរដ្ឋាភិបាល ធ្វើសំយាបថទំនាក់ទំនងឱ្យបានល្អជាមួយនឹងរាជរដ្ឋាភិបាលសៀម ដើម្បីជំរុញការដាក់ប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភពលោក នៅដើមខែកក្កដា ឆ្នាំ ២០០៨ នាទីក្រុងកេបិក ប្រទេសកាណាដា។

- ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៨ : ក្រុមប្រឹក្សាសន្តិសុខជាតិសៀម (NSC) បានធ្វើការគាំទ្រលើផែនទីប្រាសាទព្រះវិហារថ្មី ដែលប្រទេសកម្ពុជាបានធ្វើឡើង។

- ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ : រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសៀម បានចុះហត្ថលេខាព្រមព្រៀងលើសេចក្ដីថ្លែងការណ៍រួមមួយ ស្ដីពីការបញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅទីក្រុងបាងកក ប្រទេសសៀម ដែលចុះហត្ថលេខាដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី *សុខ អាន* និងរដ្ឋមន្ត្រីក្រសួងការបរទេសសៀម លោក *ណុបផាដុន ប៉ាតាម៉ា*។ សេចក្ដីប្រកាសរួមដែលទម្លាយភាពទ័លច្រកកម្ពុជា និងសៀម ក្នុងការដាក់បញ្ចូលប្រាសាទព្រះវិហារ ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនោះ មានចំនួន ៦ ចំណុច ÷

១- ព្រះរាជាណាចក្រសៀមគាំទ្រការបញ្ចូលប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលស្នើឡើងដោយកម្ពុជានៅក្នុងសម័យប្រជុំលើកទី ៣២ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក (ទីក្រុងកេបិក ប្រទេសកាណាដា នៅខែ កក្កដា ឆ្នាំ ២០០៨)។ បរិវេណនៃប្រាសាទព្រះវិហារដែលសម្គាល់ថា ជាតំបន់ ១ នៅក្នុងផែនទីគំនូស ដែលរៀបចំឡើងដោយអាជ្ញាធរកម្ពុជា ត្រូវបានភ្ជាប់ជាមួយសេចក្ដីប្រកាសរួមនេះ។ ផែនទីនេះ រួមបញ្ចូលផងដែរ នូវតំបន់ទ្រនាប់ ដែលត្រូវបានសម្គាល់ថា ជាតំបន់ ២ ដែលស្ថិតនៅទិសខាងកើត និងខាងត្បូងប្រាសាទ។

២- ក្នុងស្មារតីប្រកបដោយសុច្ឆន្ទៈ និងការសម្របសម្រួល ព្រះរាជាណាចក្រកម្ពុជា ព្រមទទួលយកការបញ្ចូលប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដោយពុំមានតំបន់ទ្រនាប់នៅផ្នែកខាងជើង និងខាងលិចនៃប្រាសាទទេនៅក្នុងពេលនេះ។

៣- ផែនទីគំនូស ដែលបានលើកឡើងក្នុងកថាខណ្ឌទី ១ ខាងលើត្រូវជំនួសផែនទីគំនូសនានា ដែលពាក់ព័ន្ធ និងរួមបញ្ចូលទាំង "គំនូសបំព្រួញមេសម្រាប់កំណត់តំបន់ប្រាសាទព្រះវិហារ" ព្រមទាំងក្រាហ្វិចយោងទាំងអស់ ដែលចង្អុលបង្ហាញ "តំបន់ស្នូល និងតំបន់កំណត់នានានៃរមណីយដ្ឋានប្រាសាទព្រះវិហារ" ក្នុងសំណុំឯកសាររបស់កម្ពុជា ដែលស្នើបញ្ចូលប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

៤- ក្នុងរយៈពេលរង់ចាំលទ្ធផលការងាររបស់គណៈកម្មការចម្រុះកិច្ចការព្រំដែន (JBC) ពាក់ព័ន្ធទៅនឹងផ្នែកខាងជើង និងខាងលិចនៃតំបន់ជុំវិញប្រាសាទព្រះវិហារ ដែលកំណត់ ថាជាតំបន់ ៣ នៅក្នុងផែនទីគំនូស ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ ខាងលើ ផែនការគ្រប់គ្រងផ្នែកទាំងនេះ នឹងត្រូវរៀបចំឡើងដោយមានការពិគ្រោះយោបល់គ្នារវាងអាជ្ញាធរកម្ពុជា និងសៀម ស្របទៅតាមស្តង់ដារអន្តរជាតិ ក្នុងកិច្ចអភិរក្សក្នុងបំណងរក្សាតម្លៃលេចធ្លោរជាសាកលនៃសម្បត្តិនេះ។ ផែនការគ្រប់គ្រងនេះត្រូវបញ្ចូលក្នុងប្លង់គ្រប់គ្រងមេចុងក្រោយនៃប្រាសាទព្រះវិហារ និងតំបន់ជុំវិញ ដែលនឹងត្រូវដាក់ជូនទៅមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោកយ៉ាងយូរបំផុត ត្រឹមថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១០ ដើម្បីឱ្យគណៈកម្មាធិការបេតិកភណ្ឌពិភពលោកធ្វើការពិចារណានៅក្នុងកិច្ចប្រជុំលើកទី ៣៤ របស់ខ្លួន នាឆ្នាំ ២០១០។

៥- ការបញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក មិនមានផលប៉ះពាល់ដល់សិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃក្នុងការងារបោះបង្គោលព្រំដែនរបស់គណៈកម្មការចម្រុះកិច្ចការព្រំដែន (JBC) នៃប្រទេសទាំងពីរនេះឡើយ។

៦- ព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ សម្ដែងនូវការកោតសរសើរយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តម *កូអ៊ីជីរ៉ូ ម៉ាស៊ូរ៉ា (Koichiro Matsura)* អគ្គនាយកអង្គការយូណេស្កូ ដែលបានជួយសម្រួលដំណើរការបញ្ចូលប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

- ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៨ : ក្រសួងការបរទេសកម្ពុជា បានរៀបចំកិច្ចប្រជុំមួយជាមួយស្ថានទូតនៃបណ្ដាប្រទេសហត្ថលេខីនៃសេចក្ដីថ្លែងការណ៍រួម អំពីបញ្ហាប្រាសាទ

ព្រះវិហារនោះ។ ក្នុងកិច្ចប្រជុំនោះ ឯកឧត្តម *ឡុង វិសាលោ* រដ្ឋលេខាធិការក្រសួងការបរទេស បានប្រាប់ដល់ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត ភារធារី តំណាងស្ថានទូតទាំងអស់ ក្នុងនោះមាន ជប៉ុន អាមេរិក ឥណ្ឌា បារាំង អូស្ត្រាលី កាណាដា គុយបា កូរ៉េខាងត្បូង អង្គការ UNDP និងសហគមន៍អឺរ៉ុប ថា ភាគីពាក់ព័ន្ធបានចុះហត្ថលេខារួចហើយ លើសេចក្តីប្រកាសរួម បន្ទាប់ពីយើងបានប្រគល់ផែនទីបរិវេណ ប្រាសាទព្រះវិហារដាក់បញ្ចូលជាមួយសេចក្តីប្រកាសរួមនោះ ហើយក្នុងផែនទីនោះក៏អត់មាននិយាយអំពីរឿងព្រំដែនរវាងប្រទេសទាំងពីរ (កម្ពុជា-សៀម) ទេ។

- ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០០៨ : ទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំធ្វើសន្និសីទសារព័ត៌មានមួយជុំវិញកិច្ចការចុះបញ្ជីជាផ្លូវការក្នុងបញ្ជីបេតិកភណ្ឌ និងផែនទីតួប្រាសាទព្រះវិហារ។

- ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៨ គណៈប្រតិភូកម្ពុជាបានចេញដំណើរទៅចូលរួមប្រជុំនៅទីក្រុងកេបិក ប្រទេសកាណាដា។

- នៅវេលាម៉ោង ០៣ និង ១៥ នាទីរសៀលថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេបិក ប្រទេសកាណាដា ត្រូវនឹង ម៉ោង ២ និង ១៥ នាទីព្រឹក ម៉ោងនៅកម្ពុជា ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨ គណៈកម្មការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ បានប្រកាសជាផ្លូវការនៃការបញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក រួមមានប្រទេសទាំង ២១ (*អូស្ត្រាលី បារ៉ែន បាបាដូស ប្រេស៊ីល កាណាដា ចិន គុយបា អេហ្ស៊ីប អ៊ីស្រាអែល ហ្ស៊កដង់ កែនយ៉ា ម៉ាដាហ្គាស្កា ម៉ូរីតានី ម៉ារ៉ុក នីហ្សេរីយ៉ា ប៉េរូ សាធារណរដ្ឋកូរ៉េ អេស្ប៉ាញ ស៊ុយអែត ទុយណេស៊ី និងសហរដ្ឋអាមេរិក*) ដែលជាសមាជិកនៃគណៈកម្មាធិការចុះបញ្ជីបេតិកភណ្ឌ ពិភពលោកបានគាំទ្រការដាក់ប្រាសាទព្រះវិហារចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក។

***សកម្មភាពខ្លះៗ ទាក់ទងនឹងកិច្ចប្រជុំអនុម័តប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភពលោក***

បើទោះបីជាសៀមតវ៉ា មិនឱ្យប្រទេសកម្ពុជាបញ្ចូលប្រាសាទ ព្រះវិហារក្នុងបញ្ជីសម្បត្តិវប្បធម៌បេតិកភណ្ឌពិភពលោក យ៉ាងណាក៏ដោយ ក៏គណៈកម្មាធិការបេតិកភណ្ឌពិភពលោកមិនយល់ព្រមតាមការជំទាស់របស់ថៃនោះទេ។ ទីបំផុត ប្រទេសកម្ពុជាទទួលបានជោគជ័យទាំងស្រុង ក្នុងការបញ្ចូលប្រាសាទបុរាណខ្មែរដ៏ល្បីល្បាញនេះ នៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ប្រទេសខ្លះ ចាត់ទុកថា សៀមជំទាស់កម្ពុជាខុសរបៀបវារៈ។ តាមការប្រាប់ឱ្យដឹងពីក្រុមការងាររបស់រាជរដ្ឋាភិបាល ដែលបានចូលរួមក្នុងកិច្ចប្រជុំនោះថា សៀមបានចាប់ផ្តើមជំទាស់ចាប់តាំងពីជុំទី ១ នៃកិច្ចប្រជុំ។ គេបានស្នើឱ្យអង្គប្រជុំពន្យាសំណើរបស់ប្រទេសកម្ពុជាសិន ដោយផ្អែកលើវិវាទព្រំដែនប្រទេសទាំង ២ មិនទាន់ដោះស្រាយចប់។ មន្ត្រីនោះបានឱ្យដឹងទៀតថា គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនេះ គ្រោងអនុម័តចុះបញ្ជីប្រាសាទព្រះវិហាររបស់ព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីម៉ោង ២ និង ៣០ នាទី រសៀលថ្ងៃទី ០៧ ខែ កក្កដា ម៉ោងនៅប្រទេសកាណាដា ត្រូវនឹងម៉ោង ១ និង ៣០នាទី ទៀបភ្លឺថ្ងៃទី ០៨ ខែ កក្កដា ម៉ោងនៅកម្ពុជា។ មន្ត្រីដដែលនេះបានបន្តទៀតថា ដោយយោងទៅលើការតវ៉ាអូសបន្លាយពេលវែងនេះហើយ ដែលធ្វើឱ្យគណៈកម្មាធិការនេះសម្រេចជាផ្លូវការឱ្យកម្ពុជា ចុះបញ្ជីប្រាសាទព្រះវិហាររបស់ខ្លួន រហូតដល់ម៉ោង ០៣ និង ១៥ នាទី រសៀល ថ្ងៃដដែល ម៉ោងនៅប្រទេសកាណាដា ត្រូវនឹងម៉ោង ០២ និង ១៥ នាទី ទៀបភ្លឺ ថ្ងៃដដែល ម៉ោងនៅកម្ពុជា។ គួររំលឹកផងដែរថា នៅខណៈពេលដែល ថៃតវ៉ាយ៉ាងខ្លាំងក្លានៅក្នុងអង្គប្រជុំនោះ សហរដ្ឋអាមេរិក ដែលជាសមាជិកសំខាន់នៅក្នុងគណៈកម្មាធិការនេះ បានលើកដៃឆ្លើយតបទៅថៃវិញឱ្យបញ្ឈប់ការជំទាស់រឿងនេះ ព្រោះការតវ៉ារបស់ថៃគ្មានមូលដ្ឋានច្បាប់ទេ។ មន្ត្រីនោះក៏បានលើកឡើងថា មុនដំបូងប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក បានសម្រេចឱ្យកម្ពុជាឡើងធ្វើបទបង្ហាញមុនគេ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី *សុខ អាន* ក៏បានឡើងមានមតិដោយមានឯកសារ ២ ទំព័រ។ គួរបញ្ជាក់ថា ប្រទេសនីមួយៗ មានសិទ្ធិនិយាយតែម្នាក់ទេ ហើយពេលវេលានៃការនិយាយ គឺកំណត់ ៣ នាទី។ ខណៈពេលដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រី *សុខ អាន* ធ្វើបទបង្ហាញរបស់ខ្លួនជុំវិញឯកសារខ្លះៗ ស្តីអំពីប្រាសាទព្រះវិហារ ស្រាប់តែលោក *ណុបផាដុន* រដ្ឋមន្ត្រីក្រសួងការបរទេសថៃ ឡើងមានមតិយ៉ាងខ្លីថា សំណើរបស់កម្ពុជា សៀមសុំជំទាស់ទាំងស្រុង។ ប៉ុន្តែលោក *ណុបផាដុន* មិនបានពន្យល់អំពីហេតុផលជំទាស់នោះទេ។ ក្រោយមកទៀត មន្ត្រីរបស់សៀមម្នាក់ក្រោកឈរឡើងជំទាស់យ៉ាងដាច់អហង្ការ ដោយពន្យល់ពីហេតុផលផ្សេងៗ អំពីបញ្ហាព្រំដែន។ ការជំទាស់របស់មន្ត្រីសៀមនេះ គឺមានលក្ខណៈធ្ងន់ធ្ងរបំផុត ដែលធ្វើឱ្យស៊ីពេលរហូតដល់ជាង ១០ នាទី។ ឃើញដូច្នេះ សហរដ្ឋអាមេរិក បានឡើងនិយាយកាត់ព្រោះការលើកឡើងរបស់គេ អត់មានឯកសារយោងជាមូលដ្ឋានរឹងមាំ ជាងនេះទៅទៀត គឺបាននិយាយរំលោភលើពេលវេលារបស់គណៈកម្មាធិការដែលបានកំណត់។ អ្វីដែលកម្ពុជាមិននឹកស្មានដល់ គឺសហរដ្ឋអាមេរិកបានគាំទ្រកម្ពុជាយ៉ាងពេញទំហឹង ចំពោះសំណើរបស់កម្ពុជា ស្តីពីការចុះបញ្ជីប្រាសាទនេះ។ មុនដំបូង គណៈកម្មាធិការ គ្រោងនឹងឱ្យវាគ្មិនអនុម័តតាមរយៈការបោះឆ្នោតសម្ងាត់ ប៉ុន្តែ ក្រោយមកសហរដ្ឋអាមេរិក ដែលជាអ្នកព្រាងរបៀបវារៈជំទាស់មិនឱ្យបោះឆ្នោត គឺឱ្យអនុម័តជាឯកច្ឆ័ន្ទ ក្រោយពេល

ដែលប្រទេសនីមួយៗធ្វើបទបង្ហាញរបស់ខ្លួនចប់។ ត្រង់ចំណុចនេះ ប្រទេសកាណាដា ដែលជាប្រធាននៃអង្គការនេះស្រាប់ ក៏បានគាំទ្រ បន្ទាប់មកទៀត ប្រទេសឥណ្ឌា អ៊ីស្រាអែល និងបណ្តាប្រទេសធំៗផ្សេងៗទៀត។ ក្រោយពីមានសម្លេងគាំទ្រលើសលប់បែបនេះ លោកស្រីប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភព-លោក បានយកញញួរគោះជួងសម្រេចឱ្យកម្ពុជា ចុះបញ្ជីប្រាសាទព្រះវិហារជាផ្លូវការចាប់ពីពេលនេះទៅ។ គួរបញ្ជាក់ថា ក្រុមការងាររបស់រដ្ឋាភិបាលកម្ពុជា ដែលបានទៅធ្វើកិច្ចការទាំងនេះមានការស្វិតស្វាញយ៉ាងខ្លាំងទម្រាំនឹងបានជោគជ័យ។ ចាប់ពីពេលនេះទៅប្រាសាទព្រះវិហារ មានឈ្មោះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកហើយ។

### *ការរារាំងពីភាគីសៀមចំពោះការដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក*

ការរារាំងមិនឱ្យប្រទេសកម្ពុជាដាក់ប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក គឺដោយសារតែលោកឧត្តមសេនីយ៍ *ពិចសានុ ពុកចាការ* អ្នកនាំពាក្យក្រសួងការពារជាតិរបស់សៀម បានប្រាប់កាសែតបាងកកប៉ុស្តិ៍ថា បើប្រទេសកម្ពុជាដាក់បញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោកនោះ នឹងធ្វើឱ្យល្អក់កករដល់ទំនាក់ទំនងកម្ពុជា-សៀម ជាមិនខាន ដោយលោកគិតថា ប្រទេសសៀមត្រូវគិតគូរពីផលប្រយោជន៍ជូនប្រទេសសៀម ហើយយើងអាចតវ៉ាតាមផ្លូវទូត ហើយព្យាយាមពន្យល់ប្រទេសដទៃថា ប្រទេសសៀមព្យាយាមសហការជាមួយប្រទេសកម្ពុជាក្នុងការស្នើសុំចុះបញ្ជីប្រាសាទនេះ ក្នុងបញ្ជីបេតិកភណ្ឌពិភព-លោកទៅទៀតផង។ តែជំហររបស់រដ្ឋាភិបាលកម្ពុជា តាមរយៈប្រសាសន៍របស់ឯកឧត្តម *ហោ ណាំហុង* រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានប្រតិកម្មតបវិញថា ប្រាសាទព្រះវិហារជាកម្មសិទ្ធិរបស់កម្ពុជា ដែលជាសិទ្ធិសម្រេចរបស់កម្ពុជាតែមួយគត់ ក្នុងការដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក ហើយឯកឧត្តម *ខៀវ កញ្ញារីទ្ធ* អ្នកនាំពាក្យរដ្ឋាភិបាល និងជារដ្ឋមន្ត្រីក្រសួងព័ត៌មាន បានបញ្ជាក់ពីគោលជំហររដ្ឋាភិបាលកម្ពុជាថា បើទោះជាប្រទេសសៀម នៅតែបដិសេធមិនឱ្យដាក់ បញ្ចូលប្រាសាទនេះជាបេតិកភណ្ឌពិភពលោកក៏ដោយ ក៏យើងនៅតែបន្តនីតិវិធីនេះតទៅទៀតដែរ[៥]។ តុលាការប្រជាជនសៀមបាន បង្គាប់ឱ្យរដ្ឋាភិបាលសៀមដកការគាំទ្រប្រទេសកម្ពុជា ក្នុងការចុះបញ្ជីប្រាសាទព្រះវិហារនេះ តែលោក *សាម៉ាក់ ស៊ុនដារ៉ាវេជ* នាយករដ្ឋមន្ត្រីសៀម បានថ្លែងជាផ្លូវការទៅ កាន់ប្រជាជនសៀម កាលពីថ្ងៃអាទិត្យទី ០៦ ខែ កក្កដា ឆ្នាំ ២០០៨ ថាមានតែគណៈកម្មាធិការបេតិកភណ្ឌពិភពលោករបស់ អង្គការយូណេស្កូទេ ដែលមានសិទ្ធិសម្រេច ហើយលោកបានហៅការរារាំងរបស់ក្រុមចលនាប្រជាជនដើម្បីលទ្ធិប្រជាធិបតេយ្យថា គ្រាន់តែជាការបង្កអរិភាពរវាងកម្ពុជា-សៀម និងដើម្បីទម្លាក់អតីតនាយករដ្ឋមន្ត្រីសៀម *ថាក់ស៊ីន ស៊ីណាវ៉ាត់* តែប៉ុណ្ណោះ[៦]។

បន្ទាប់ពី សមាជិកគណៈកម្មាធិការបេតិកភណ្ឌពិភពលោក បានគាំទ្រចំពោះការបញ្ចូលប្រាសាទព្រះវិហារ នៅទីក្រុងកេបិកប្រទេសកាណាដាភ្លាមមក រដ្ឋមន្ត្រីការបរទេសសៀម *ណុបផាដុន ផាត់ថាម៉ា* បានជំទាស់ តែគណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានចាត់ទុកជាការជំទាស់គ្មានប្រសិទ្ធភាព។[៧]

ប្រទេសសៀមបានជំទាស់ទៅនឹងសំណើនោះ ដោយសំអាងលើហេតុផលថា ព្រំដែននៅជុំវិញប្រាសាទនោះ នៅមានជម្លោះនៅឡើយ។

- គណៈកម្មាធិការកិច្ចការបរទេសនៃព្រឹទ្ធសភាសៀមនឹងដាក់សំណើទៅកាន់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ ដើម្បីសុំពន្យារពេលនៃការចុះបញ្ជីប្រាសាទព្រះវិហារចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ដោយលើកហេតុផលថា ក្រសួងការបរទេសសៀមបានរំលោភលើរដ្ឋធម្មនុញ្ញ ដែលតម្រូវឱ្យមានការអនុម័តយល់ព្រមពីសភា ចំពោះកិច្ចព្រមព្រៀងណា ដែលប៉ះពាល់ដល់ទឹកដីរបស់ថៃ ហើយក្រសួងការបរទេសរបស់ខ្លួន ខ្វះតម្លាភាពក្នុងការដោះស្រាយបញ្ហានោះ។
- ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៨ ក្រុមអ្នកប្រឆាំងរបស់សៀម បានសុំធ្វើបាតុកម្មនៅច្រកទ្វារព្រំដែនប្រាសាទព្រះវិហារ ដោយធ្វើដំណើរចេញពីហាន់ដាឡាក់ខេត្តអ៊ូប៊ុន។ ប៉ុន្តែទោះជាយ៉ាងណាក្តី អាជ្ញាធរថៃបានរារាំងមិនឱ្យមកដល់ច្រកនេះទេ។ ពោលគឺគេអនុញ្ញាតឱ្យធ្វើបាតុកម្មតែត្រឹមផ្សាររបស់សៀម ដែលមានចម្ងាយប្រមាណជា ១ គីឡូម៉ែត្រ ពីច្រកទ្វារព្រំដែន។
- ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៨ ក្រុមបាតុករសៀមចូលមកធ្វើបាតុកម្មនៅចម្ងាយ ២០ ម៉ែត្រ ពីច្រកទ្វារព្រំដែន ដែលធ្វើឱ្យអាជ្ញាធរកម្ពុជា សម្រេចបិទច្រកព្រំដែន នៅល្ងាចថ្ងៃដដែលនោះ។
- ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០០៨ តុលាការរដ្ឋបាលសៀមបានចេញសេចក្តីបង្គាប់មួយ ដោយបញ្ជាឱ្យរដ្ឋាភិបាលសៀម

[៥] វិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៨ http://www.voanews.com/Khmer/archive/2008-01/2008-01-25-voa2.cfm

[៦] វិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិកថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨។

[៧] វិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨។

ឱ្យបញ្ឈប់ជាបណ្តោះអាសន្ន នូវការអនុវត្តសកម្មភាពណាមួយ បន្ថែមទៀត ដែលពាក់ព័ន្ធទៅនឹងការគាំទ្រចំពោះផែនទីថ្មីនៃប្រាសាទព្រះវិហារ ដែលគូសដោយប្រទេសកម្ពុជា ។

- ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៨ សមាជិក ព្រឹទ្ធសភាសៀមមួយក្រុម ដែលមានគ្នា ៧៧ នាក់ បានចាប់ផ្តើមដំណើរការបញ្ឈប់ការគាំទ្ររដ្ឋាភិបាលសៀម ចំពោះសំណើរបស់រដ្ឋាភិបាលកម្ពុជា ដែលស្នើដាក់ប្រាសាទព្រះវិហារចូលទៅក្នុងបញ្ជីបេតិក-ភណ្ឌពិភពលោក ដោយបានបញ្ជូនសេចក្តីទាមទាររបស់ពួកគេទៅកាន់តុលាការធម្មនុញ្ញសៀម តាមរយៈប្រធានព្រឹទ្ធសភា លោក *ប្រសព្វសុខ បណ្ឌិត* ដើម្បីស្នើឱ្យតុលាការនេះ ចាត់ទុកជាមោឃៈនូវសេចក្តីថ្លែងការណ៍រួមមួយ ដែលរាជរដ្ឋាភិបាលសៀមបានចុះហត្ថ លេខាជាមួយប្រទេសកម្ពុជាក្នុងការគាំទ្រសំណើខាងលើ ។

### ប្រាសាទព្រះវិហារក្លាយជាបេតិកភណ្ឌពិភពលោក

យោងតាមសន្ធិសញ្ញាឆ្នាំ ១៩០៧ និងផែនទី ដែលគូសនៅឆ្នាំ ១៩០៨ និងសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៦២ ដែលចាត់ទុកថា ប្រាសាទព្រះវិហារជារបស់ខ្មែរ ។ តាមរយៈការខិតខំប្រឹងរបស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានព្យាយាមដាក់បញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដោយធ្វើការបញ្ចុះបញ្ចូល និងស្វែងរកការគាំទ្រពីបណ្តាប្រទេសជាសមាជិក នៃមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ និងដោយផ្អែកលើចំណុចសំខាន់ ២ គឺ :

១- សេក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ ក្រុងឡាអេ ឆ្នាំ ១៩៦២ ។ ប្រទេសកម្ពុជាជាប្រទេសមានអធិប-តេយ្យភាព ដូច្នេះ ប្រាសាទព្រះវិហារជាកម្មសិទ្ធរបស់ខ្មែរ ។

២- កម្ពុជាបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌរបស់អង្គការយូណេស្កូ ។

ទោះបី មានការតវ៉ាប្រឆាំងជំទាស់ពីសំណាក់ភាគីសៀមជាច្រើនលើកច្រើនសា ចំពោះសំណើការដាក់ប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភពលោកយ៉ាងណាក៏ដោយ ក៏ការព្យាយាមប្រឆាំងជំទាស់របស់ថៃ ក្នុងការស្នើសុំឱ្យអង្គការយូណេស្កូពន្យារពេល ក្នុងការដាក់ប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភព-លោក មិនបានសម្រេចទេ ។ ទីបំផុត នៅវេលាម៉ោង ០៣ និង ១៥ នាទី រសៀល ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេបិក ប្រទេសកាណាដា ត្រូវនឹងម៉ោង ០២ និង ១៥ នាទីព្រឹក ម៉ោងនៅកម្ពុជា ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨ អង្គការយូ-ណេស្កូបានសម្រេចចុះបញ្ជីប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភពលោកជាឱ្យឡារិកចាប់ពីពេលនោះតទៅ ។

ដូច្នេះ ការសម្រេចដាក់ប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភពលោកនេះ គឺមិនមែនផ្អែកលើការគាំទ្រ ឬមិនគាំទ្រពីសំណាក់ពីភាគីថៃទេ ព្រោះថាប្រាសាទព្រះវិហារជារបស់ខ្មែរ ។ម្យ៉ាងទៀត ការដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូនេះ គឺដោយសារតែការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបានអនុវត្តទៅតាមលក្ខខណ្ឌទាំងបីចំណុចរបស់យូណេស្កូ គឺ :

១- រៀបចំអភិរក្សប្រាសាទនេះឱ្យបានល្អ

២- រៀបចំបញ្ជីឯកសារស្នើសុំឱ្យបានត្រឹមត្រូវ

៣- ដោះស្រាយវិវាទរវាងប្រទេសកម្ពុជា និងសៀមឱ្យបានត្រឹមត្រូវ ។

ជារួម លក្ខខណ្ឌទាំងនោះ គឺសំដៅទៅលក្ខណៈសម្បត្តិនៃប្រាសាទនេះ ដែលអាចចូលបានដោយសារតែប្រាសាទនេះមានតម្លៃជាសកលលោក ដែលអង្គការយូណេស្កូបានធ្វើការវាយតម្លៃរួចហើយ ។ ហើយចំពោះការដោះស្រាយវិវាទជាមួយភាគីសៀមក្នុងការដោះស្រាយបញ្ហាផ្សេងៗ គឺកម្ពុជាបានប្រកាន់ជំហរដោះស្រាយដោយសន្តិវិធី ហើយជាពិសេស ចំពោះការវាយតម្លៃរបស់ ICOMOS ដែលបានចាត់ទុកប្រាសាទព្រះវិហារថាមានតម្លៃជាសកល ជាសម្បត្តិមនុស្សជាតិលើសកលលោក ។

ចំពោះការចុះបញ្ជីប្រាសាទព្រះវិហារ ចូលជាបេតិកភណ្ឌពិភពលោក នឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើន ចំពោះប្រទេសកម្ពុជា គឺ :

- ជាមោទនភាពជាតិខ្មែរ ដែលមានប្រាសាទព្រះវិហារខ្មែរមួយទៀត បន្ទាប់ពីប្រាសាទអង្គរវត្ត ដែលត្រូវទទួលស្គាល់នូវតម្លៃជាសកលអំពីស្ថាបត្យកម្មខ្មែរ ដោយអង្គការយូណេស្កូ និងរឹតតែធ្វើឱ្យប្រជាជនលើពិភពលោក ស្គាល់ប្រទេសខ្មែរកាន់តែច្បាស់ថែមទៀត ។

- ប្រាសាទព្រះវិហារនឹងបានទទួលធនធានហិរញ្ញវត្ថុ និងធនធានបច្ចេកទេសជំនាញជាន់ខ្ពស់ សម្រាប់ថែរក្សាការពារឱ្យបានគង់វង្ស ទុកជាកេរដំណែលសម្រាប់កូនខ្មែរជំនាន់ក្រោយ ក៏ដូចជាកេរដំណែលរបស់មនុស្សជាតិទាំងមូលផងដែរ ។

- ប្រជាជនខ្មែរនឹងបានប្រាក់ចំណូលពីភ្ញៀវទេសចរ ដែលមកទស្សនាប្រាសាទនេះ និងធ្វើឱ្យមានកំណើនសេដ្ឋកិច្ចថែមទៀត ។

- ជាសក្ខីភាពបញ្ជាក់កាន់តែច្បាស់ថាប្រាសាទព្រះវិហារគឺជាប្រាសាទរបស់ខ្មែរតែម្នាក់គត់ ដែលយើងអាចនិយាយបានថា ជាសាលក្រមអន្តរជាតិទី ២ បន្ទាប់សាលក្រមរបស់តុលាការយុត្តធម៌អន្តរជាតិ ទីក្រុងឡាអេ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៦២ និងជាការដាស់សតិជនជាតិខ្មែរមួយចំនួន ដែលពីមុនមិនសូវចាប់អារម្មណ៍ ឬមិនស្គាល់ប្រាសាទព្រះវិហារ ឱ្យមានការចាប់អារម្មណ៍ និងស្គាល់ប្រាសាទនេះឡើងវិញ ។




Map used by the Kingdom of Cambodia based on the Map recognized by the ICJ as **an intergral part** of the treaty settlement in its judgment of 15 June 1962

**ផែនទីតំបន់ប្រាសាទព្រះវិហារ ដែលទទួលស្គាល់ជាអន្តរជាតិ**




Recent map for the same area **unilaterally** prepared and presented by the Kingdom of Thailand. The yellow colored area indicates the claim by Thailand.

**ផែនទីតំបន់ប្រាសាទព្រះវិហារ ដែលប្រទេសថៃគូរដោយឯកតោភាគី**

## *ក្តីរំភើប ដែលបញ្ចប់ដោយការឈឺចាប់*

បន្ទាប់ពីប្រាសាទព្រះវិហារ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដំណឹងល្អនេះ បានផ្សព្វផ្សាយភ្លាមៗនៅទូទាំងប្រទេសតាមរយៈបណ្តាញទូរទស្សន៍ CTN។ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបនៅទូទាំងប្រទេស បានសម្តែងនូវក្តីរំភើប និងសប្បាយរីករាយយ៉ាងក្រៃលែង។ គ្រប់វត្តអារាមបានទូងស្គរដើម្បីអបអរសាទរផងដែរ។



**ប្រជាពលរដ្ឋអបអរសាទរការចុះបញ្ជីប្រាសាទព្រះវិហារ ជាបេតិកភណ្ឌពិភពលោក**

សម្តេចនាយករដ្ឋមន្ត្រី *ហ៊ុន សែន* បានសម្តែងការអបអរសាទរ ចំពោះការចុះប្រាសាទព្រះវិហារចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ។ ក្នុងសារមួយផ្ញើជូនជនរួមជាតិ នៅថ្ងៃអង្គារ ទី ០៨ កក្កដា ឆ្នាំ ២០០៨ គឺ មួយថ្ងៃ បន្ទាប់ពីអង្គការយូណេស្កូ បានសម្រេចដាក់បញ្ចូលប្រាសាទព្រះវិហារជាទីសក្ការៈរបស់ខ្មែរ ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក សម្តេច បានចាត់ទុកការចុះបញ្ជីនេះថា គឺជាមោទនភាពថ្មីមួយទៀត សម្រាប់ប្រជាពលរដ្ឋ និងព្រះរាជាណាចក្រកម្ពុជា។ សម្តេច បានបន្តថា នេះជាបេតិកភណ្ឌខ្មែរទី ៤ ហើយ ដែលត្រូវបានទទួលលក្ខន្តិកៈដ៏ខ្ពង់ខ្ពស់ និងថ្លៃថ្នូរនេះ បន្ទាប់ពីប្រាសាទអង្គរវត្ត ត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដូចគ្នាដែរ នៅឆ្នាំ ១៩៩២ របាំក្បាច់បុរាណខ្មែរ (របាំព្រះរាជទ្រព្យ) ត្រូវបានបញ្ចូលជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ នៅឆ្នាំ ២០០៣ និងល្ខោនស្បែកធំ នៅឆ្នាំ ២០០៥ កន្លងទៅ។

នៅក្នុងសន្និសីទកាសែត នាទីស្តីការក្រសួងការបរទេសឯណោះវិញនៅព្រឹកថ្ងៃអង្គារនោះដែរ ឯកឧត្តម *ហោ ណាំហុង* ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបង្ហាញនូវក្តីសប្បាយរីករាយយ៉ាងខ្លាំង។ ឯកឧត្តម បានថ្លែងថា "នេះជាជោគជ័យមួយរបស់រាជរដ្ឋាភិបាល។ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺថា វាជាជោគជ័យនៃអារ្យធម៌ខ្មែរ"។

ក្រុមនិស្សិត និងប្រជាពលរដ្ឋនៅក្រុងភ្នំពេញ បានគ្រវីទង់ជាតិកម្ពុជានៅតាមវិធីនានា ដើម្បីអបអរការបញ្ចូលប្រាសាទព្រះវិហារជាទីសក្ការៈទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ពួកគេបានចាត់ទុកថា វាជាថ្ងៃសប្បាយសម្រាប់ប្រទេសកម្ពុជា។

ស្របពេលដែលរាជធានីភ្នំពេញ កំពុងតែប្រារព្ធពិធីអបអរសាទរយ៉ាងសប្បាយរីករាយ ចំពោះការបញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនោះ ផ្ទៃមេឃនៅព្រឹកថ្ងៃអង្គារស្រទំមិនមានកម្ដៅក្ដៅឡើយដោយគេសង្កេតឃើញមានថ្ងៃបាំងឆត្រកើតមាន ខណៈពេលមានការចាក់ផ្សាយសាររបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ កាសែតកោះសន្តិភាពសរសេរថា ថ្ងៃបាំងឆត្រនោះបានរះមូលក្រឡង់

និងច្បាស់ក្រឡែត នៅពេលដែលប្រជាជនទូទាំងក្រុងភ្នំពេញកំពុងតែប្រារព្ធពិធីអបអរសាទរនៅគ្រប់ទីកន្លែង។ មតិខ្លះគិតថា នេះគឺជាមហិទ្ធិឫទ្ធិរបស់ប្រាសាទព្រះវិហារ បញ្ចេញឫទ្ធិអំណាច ដែលជាដួងព្រលឹងជាតិយ៉ាងពិតប្រាកដ។ ក្រៅពីពេលព្រឹកដែលមានថ្ងៃបាំងឆត្រនោះ នៅពេលរសៀល ក៏មានភ្លៀងមួយមេធំបានធ្លាក់ស្រោចស្រព មកលើទីក្រុងភ្នំពេញផងដែរ ហាក់ដូចជាព្រះភិរុណ បានចូលរួមអបអរសាទរការបញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ជាមួយប្រជាពលរដ្ឋកម្ពុជាដែរ។ ភ្លៀងបានធ្លាក់រហូតដល់ពេលយប់ ខណៈដែលមានការប្រគុំតន្ត្រីនៅរមណីយដ្ឋានវត្តភ្នំ ដែលសាលាក្រុងភ្នំពេញបានរៀបចំឡើង ដើម្បីអបអរសាទរព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ។

ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨ ប្រទេសកម្ពុជាបានរៀបចំពិធីទទួលពិធីស្វាគមន៍យ៉ាងកក់ក្ដៅ ជូនចំពោះគណៈប្រតិភូអញ្ជើញមកពីចូលរួមក្នុងកិច្ចប្រជុំរបស់អង្គការយូណេស្កូ លើកទី៣២ នៅទីក្រុងកេបិក ប្រទេសកាណាដា ដែលដឹកនាំដោយឯកឧត្ដម *សុខ អាន* ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី។

មួយថ្ងៃក្រោយមក គឺនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨ ទាហានឈុតខ្មៅសៀមបានសម្រុកចូលមកក្នុងទឹកដីខ្មែរ ដោយចូលមកនៅក្នុង "វត្តកែវសិក្ខាគិរីស្វារៈ" ហៅ "វត្តប្រាសាទ"។ ការលើកទ័ពចូលក្នុងវត្ត ដែលជាទឹកដីខ្មែរនេះ គឺជាការឈ្លានពានមកលើអធិបតេយ្យភាពរបស់ខ្មែរ និងបង្កឱ្យមានភាពតានតឹងនៅតំបន់ជុំវិញប្រាសាទព្រះវិហារ។



**ទាហានឈុតខ្មៅសៀមសម្រុកចូលវត្តកែវសិក្ខាគិរីស្វារៈរបស់ខ្មែរ កាលពីថ្ងៃទី ១៥ កក្កដា ឆ្នាំ ២០០៨**

អំពើឈ្លានពានដ៏កម្រោលនេះ ធ្វើឱ្យប្រជាពលរដ្ឋខ្មែរមានការឈឺចាប់យ៉ាងខ្លាំង និងបានថ្កោលទោសយ៉ាងពេញទំហឹង។ នៅយប់ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨ នោះ ប៉ុន្មានម៉ោងក្រោយការរំលោភបំពានរបស់ទាហានឈុតខ្មៅសៀម មកលើអធិបតេយ្យភាពរបស់កម្ពុជា វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា បានចេញចេញសេចក្ដីថ្លែងការណ៍មួយ ដោយបានចាត់ទុកសកម្មភាពរបស់ទាហានឈុតខ្មៅសៀម រំលោភយ៉ាងធ្ងន់ធ្ងរចំពោះអធិបតេយ្យភាព និងបូរណភាពដែនដីស្របច្បាប់របស់ព្រះរាជាចក្រកម្ពុជា ក៏ដូចជាច្បាប់អន្តរជាតិ ហើយក៏ជាការប្រមាថយ៉ាងធ្ងន់ធ្ងរចំពោះប្រជាជាតិកម្ពុជា។

ទាហានឈុតខ្មៅថៃមិនត្រឹមតែមិនបានដកថយចេញពីវត្តកែវសិក្ខាគិរីស្វារៈប៉ុណ្ណោះទេ ថែមទាំងលើកទ័ពជាច្រើនចូលមកបន្ថែមជាបន្តបន្ទាប់ និងបានប្រកាសជាឯកតោភាគីថា វត្តកែវសិក្ខាគិរីស្វារៈ និងតំបន់ជុំវិញជាទឹកដីរបស់ខ្លួនទៀតផង។ ទោះជាយ៉ាងណាក្ដី ពុំមានការផ្ទុះអាវុធណាមួយនោះទេ ហើយដំណោះស្រាយជាច្រើន ត្រូវបានធ្វើឡើងតាមការចរចាក្នុងក្របខ័ណ្ឌទ្វេភាគី តែមិនសូវបានលទ្ធផលជាដុំកំភួននោះទេ ហើយសភាពការណ៍ក៏មិនបានវិលត្រឡប់ដូចមុនថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៨ នៅឡើយ គឺមានតែការចរចាម្ដងហើយម្ដងទៀតតែប៉ុណ្ណោះ...!

### *ដំណើរការចរចាមានល្បឿនដូចរ៉ឺឡាកិនថ្នល់*

ទោះបីមានបញ្ហាប្រឈមដាក់គ្នាយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាកកម្ពុជា ប្រកាន់នូវគោលជំហរក្នុងការដោះស្រាយបញ្ហាដោយសន្តិវិធី និងឱ្យកងកម្លាំងប្រដាប់អាវុធខ្មែរទាំងអស់មានភាពអត់ធ្មត់ ព្រោះរាជរដ្ឋាភិបាលយល់ឃើញថា គ្មានដំណោះស្រាយអ្វីប្រសើរជាងការចរចាគ្នានោះទេ។ ការចរចាដែលមិនសូវបានលទ្ធផលទាំងនោះ ត្រូវបានធ្វើជាបន្តបន្ទាប់ដូចខាងក្រោម :

- ជំនួបលើកទី ១ ការចរចាថ្នាក់រដ្ឋមន្ត្រីការពារជាតិរវាងប្រទេសទាំងពីរ នៅខេត្តស្រះកែវ ប្រទេសសៀម នាថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៨។
- ជំនួបលើកទី ២ ការចរចាថ្នាក់រដ្ឋមន្ត្រីការបរទេស នៅខេត្តសៀមរាប ប្រទេសកម្ពុជា នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨។
- ជំនួបលើកទី ៣ ការចរចាថ្នាក់មេបញ្ជាការកងទ័ពកម្ពុជា-ថៃ នៅខេត្តសុរិន្ទ ប្រទេសសៀម នាថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨។
- ជំនួបលើកទី ៤ ការចរចាថ្នាក់រដ្ឋមន្ត្រីការបរទេស នៅហួហ៊ិន ប្រទេសសៀម នាថ្ងៃទី ១៨-១៩ ខែ សីហា ឆ្នាំ ២០០៨។

លទ្ធផលនៃការចរចានេះ គឺបានត្រឹមតែការកែសម្រួលទ័ពនៅតំបន់ប្រាសាទព្រះវិហារ ដោយឱ្យចំនួនទ័ពនៃភាគីទាំងពីរ រក្សាទុកនៅក្នុងវត្ត ត្រឹមចំនួន ១០ នាក់ និង នៅក្រៅបរិវេណវត្ត ត្រឹមចំនួន ២០ នាក់ ទាំងសង្ខាង ហើយនឹងមានការចរចាជាបន្តបន្ទាប់ទៀត ដើម្បីធ្វើយ៉ាងណាឱ្យស្ថានការណ៍ដូចកាលពីមុន

ថ្ងៃទី ១៩ ខែ កក្កដា បានន័យថា កងទ័ពសៀម ដែលធ្លាប់នៅកន្លែងណា ទៅនៅកន្លែងដើមនោះវិញ ។ ជាមួយគ្នានោះដែរ ភាគីទាំងពីរ បានសម្រេចយក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៨ ដើម្បីជួបប្រជុំគ្នាថ្នាក់គណៈកម្មការព្រំដែន នៅក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា ប៉ុន្តែភាគីសៀមបានសុំលើកកិច្ចប្រជុំនេះ ទៅពេលក្រោយ ដោយសំអាងទៅលើបញ្ហាវិបត្តិនយោបាយនៅក្នុងប្រទេសខ្លួន។ តាំងពីនោះមក មិនទាន់មានយន្តការណាមួយ សម្រាប់ដោះស្រាយទំនាស់នៅឡើយ ។ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជានៅតែមានឆន្ទៈដោះស្រាយទំនាស់ដោយសន្តិវិធី ។

***សាស្ត្រាចារ្យបណ្ឌិត រស់ ចន្ត្រាបុត្រ : សៀមប្រើយុទ្ធសាស្ត្រអូសបន្លាយពេល ដើម្បីបង្ហិតបង្ហិចទឹកដីបន្ថែមទៀត***



**សាស្ត្រាចារ្យបណ្ឌិត រស់ ចន្ត្រាបុត្រ**

ការប្រើយុទ្ធសាស្ត្រអូសបន្លាយពេលរបស់សៀម ក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសកម្ពុជា ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត *រស់ ចន្ត្រាបុត្រ* អនុប្រធាន រាជបណ្ឌិតសភាកម្ពុជា និងជាប្រធានស្តីទី នៃគណៈកម្មការគ្រប់គ្រងថ្នាក់បណ្ឌិតបង់វិភាគទានស្រាវជ្រាវ នៅរាជបណ្ឌិតសភាកម្ពុជា (ប.វ.ស) បានបញ្ចេញទស្សនៈថា :

- សៀមចង់បន្តអូសបន្លាយពេលវេលាឱ្យបានយូរ ដើម្បីកុំឱ្យកម្ពុជាប្ដឹងទៅសហគមន៍អន្តរជាតិ មានក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ និងអង្គការយូណេស្កូ ជាដើម ដើម្បីឱ្យចៀសវាង កុំឱ្យមានការថ្កោលទោសជាអន្តរជាតិទៅលើប្រទេសខ្លួន ដែលបានបញ្ជូនកងទ័ពឱ្យមកឈ្លានពានរំលោភចូលមកក្នុងទឹកដី និងអធិបតេយ្យភាពកម្ពុជា។

- សៀមចង់ស្រោចស្រង់នយោបាយខុសឆ្គងរបស់ខ្លួន ដែល បានដាក់កងទ័ពឈ្លានពានមកក្នុងទឹកដីកម្ពុជា និងក្នុងទីតាំងសម្បត្តិបេតិកភណ្ឌពិភពលោក ( ប្រាសាទព្រះវិហារ) ដើម្បីធ្វើយ៉ាងណា ឱ្យសហគមន៍អន្តរជាតិបំភ្លេចបន្តិចម្តងៗនូវព្រឹត្តិការណ៍រំលោភបំពាននេះ ។

- ក្នុងការប្រើយុទ្ធសាស្ត្រពន្យារការចរចានេះ ប្រទេសថៃមានគោលបំណងការពារផលប្រយោជន៍សេដ្ឋកិច្ច និងមុខមាត់របស់សៀមនៅលើឆាកអន្តរជាតិ ។

- យុទ្ធសាស្ត្រពន្យារការចរចានេះ អាចអនុញ្ញាតឱ្យសៀមអាចពង្រឹងទីតាំង និងការឈ្លានពានរបស់ខ្លួនមក លើកម្ពុជាព្រមទាំងបន្តការឈ្លានពាន និងគ្រប់គ្រងទឹកដីកម្ពុជានៅតាមចំណុចព្រំដែនរបស់កម្ពុជាបន្ថែមទៀត ដូចករណីការរំលោភដាក់កងទ័ពចូលក្នុងទឹកដីកម្ពុជា ចំណុចច្រកជាំស្រងាំ ចំណុចច្រកតាថាវ ចំណុចប្រាសាទតាមាន់ និងចំណុចប្រាសាទតាក្របីជាដើម ហើយដាយថាហេតុ យូរៗទៅពិបាកនឹងដោះស្រាយ និងបណ្តេញចេញពីទឹកដីកម្ពុជា ជាមិនខាននាពេលអនាគត ។

ដូច្នេះ កម្ពុជាគួរកំណត់ពេលវេលា ពោលគឺ កំណត់ឱសានវាទដល់ប្រទេសសៀម ឱ្យដកកងទ័ពជាបន្ទាន់ចេញពីអធិបតេយ្យកម្ពុជា ហើយមិនត្រូវផ្តល់ឱកាសឱ្យសៀម ម្តងហើយម្តងទៀត ឬឱ្យសៀមជាភាគីកំណត់ពេលវេលា ក្នុងការដកកងទ័ពឈ្លានពានរបស់ខ្លួននោះទេ ។ ម្យ៉ាងទៀតត្រូវបញ្ជាក់ប្រាប់ភាគីសៀមឱ្យច្បាស់លាស់ អំពីការរក្សាស្ថានភាពទ័ពឱ្យនៅជាធម្មតា និងហាមចល័តកម្លាំងទ័ព នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ទោះបីក្រោមរូបភាពជាសមយុទ្ធក៏ដោយ ដែលអាចនាំឱ្យមានការផ្ទុះអាវុធដាយថាហេតុ ។

ដើម្បីដាក់គំនាបដល់ភាគីសៀម ឱ្យទទួលយកនូវលក្ខខណ្ឌខាងលើនេះ កម្ពុជាគួរតែ :

- ត្រូវបន្តប្តឹងទៅសហគមន៍អន្តរជាតិមានសមាគមអាស៊ាន (ASEAN) សហប្រធានទាំងពីរ ( បារាំង-ឥណ្ឌូនេស៊ី) នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩១ និងជាពិសេសក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឱ្យធ្វើការព្រមាន និងកំណត់កាលបរិច្ឆេទមួយ ឱ្យទៅប្រទេសថៃ ដើម្បីដកកងទ័ពឈ្លានពានរបស់ខ្លួនចេញពីប្រទេសកម្ពុជា។

- ត្រូវបិទច្រកព្រំដែនកម្ពុជា-សៀមជាបណ្តោះអាសន្ន រហូតដល់មានការដកកងទ័ពឈ្លានពានរបស់ថៃ ។ តែទន្ទឹមនឹងនោះ យើងត្រូវរក្សាឱ្យបាននូវភាពស្ងប់ស្ងៀមកុំឱ្យមានអំពើហិង្សា និងការផ្ទុះអាវុធ ។ ម្យ៉ាងទៀត យើងគួរតែពិចារណាផងដែរ អំពីវិធានការថ្មីរបស់សៀមក្នុងពេលបច្ចុប្បន្ននេះ ដែលកំណត់ការនាំចេញបន្លែ ផ្លែឈើ ចូលមកក្នុងប្រទេសកម្ពុជា។ ទង្វើនេះ បើតាមការពិចារណារបស់យើង គឺមានគោលបំណងក្នុងការធ្វើឱ្យ រាំងស្ទះដល់ការផ្គត់ផ្គង់សេវាកម្មម្ហូបអាហារនៅតាមសណ្ឋាគារ ។ ដូច្នេះ គឺចង់បំផ្លាញឧស្សាហកម្មទេសចរណ៍កម្ពុជា។

- ត្រូវបន្តផ្សព្វផ្សាយឱ្យបានទូលាយ ឬមានកម្មវិធីតាមប្រព័ន្ធផ្សព្វផ្សាយនានាជាប្រចាំ ដើម្បីផ្តល់ព័ត៌មាន ស្តីពីតំបន់ប្រាសាទព្រះវិហារ ដើម្បីឱ្យព័ត៌មាននៅក្តៅៗជានិច្ច ដើម្បីទាក់ទាញមតិជាតិ ពិសេស មតិអន្តរជាតិ កុំឱ្យភ្លេចជុំវិញបញ្ហាការរំលោភបំពានរបស់កងទ័ពសៀមនៅតំបន់ប្រាសាទព្រះវិហារ ។

*បើសិនជាស្ថានការណ៍នេះ នៅតែអូសបន្លាយពេលវេលាតទៅទៀត នឹងធ្វើឱ្យកម្ពុជាខាតបង់ ឬបាត់បង់ប្រៀបឈ្នះ និងឱកាសឈ្នះក្នុងការដោះស្រាយបញ្ហាដ៏ធំនេះ ។*

*ប្រៀបឈ្នះ ដែលកម្ពុជាកំពុងមានច្រើនយ៉ាងលើភាគីសៀម* នោះគឺ :

- ផ្នែកផ្លូវច្បាប់

- ផ្នែកការទូត ពីសហគមន៍អន្តរជាតិ ដែលកំពុងរង់ចាំមើលឥតដាច់ អំពីឥរិយាបទដោះស្រាយរបស់សៀម ។

- សភាពការណ៍នយោបាយផ្ទៃក្នុងប្រទេសកម្ពុជាល្អប្រសើរក្រោយការបោះឆ្នោត ។ រីឯប្រជាពលរដ្ឋមានភាពស្ងប់អារម្មណ៍ជាងមុនបោះឆ្នោត ។

- កម្លាំងសាមគ្គីភាពផ្ទៃក្នុងរបស់កម្ពុជាយ៉ាងផុលផុសតាមរយៈការចូលរួមផ្ដល់អំណោយ និងសួរសុខទុក្ខដោយផ្ទាល់ដល់ទីតាំងឥតដាច់ និងពីគ្រប់ទិសទី ។

- ចិត្តសាស្ត្រកងទ័ព ដែលកំពុងពុះពារឈរការពារទឹកដីនៅសមរភូមិជួរមុខ ។

- ពត៌មានពីកងទ័ពជួរមុខរបស់សៀម កំពុងតែបាក់ទឹកចិត្ត មានជំងឺរាតត្បាតជាបន្តបន្ទាប់ រហូតដល់មានស្លាប់ទៅទៀត ។

ដូច្នេះ ដើម្បីចៀសវាងការបាត់បង់ប្រៀបឈ្នះ និងឱកាសឈ្នះជាយថាហេតុណាមួយ កម្ពុជាត្រូវបញ្ចប់នូវការអូសបន្លាយពេលវេលារបស់ថៃក្នុងការដោះស្រាយបញ្ហា ព្រោះព្រឹត្តិការណ៍នេះ កំពុងតែក្ដៅលើមតិអន្តរជាតិ ហើយបើពន្យាពេលតទៅទៀត ព្រឹត្តិការណ៍នេះនឹងក្លាយជាត្រជាក់ ហើយអាចនឹងលែងទទួលការចាប់អារម្មណ៍ពីសហគមន៍អន្តរជាតិទៀត ។ ម្យ៉ាងវិញ ទៀតសៀមក៏អាចពង្រឹងកម្លាំងនៅតាមព្រំដែន ហើយនឹងរកបាននូវយុទ្ធសាស្ត្រថ្មីបន្ថែមទៀត ។ បើដូច្នេះមែននឹងធ្លាក់លើអ្វី ដែលសៀមចង់បាន ។ ម្យ៉ាងទៀត ការពន្យារពេលនេះនឹងធ្វើប្រទេសសៀមពង្រឹងនយោបាយផ្ទៃក្នុងរបស់គេបាន ហើយបែរមកទប់ទល់នឹងកម្ពុជាវិញថែមទៀត ហើយដល់ពេលនោះ សៀមអាចកែប្រែ ឬលែងគោរពកកិច្ចសន្យានានា ដែលបានសម្រេចរួចមកហើយនោះ ដូចដែលគេបានធ្វើកន្លងមក និងថ្មីៗនេះ (ករណីការទន្ទ្រាន ដាក់កងទ័ពចូលក្នុងទឹកដីកម្ពុជា ការបន្ថែមកម្លាំងទ័ពឥតឈប់ឈរ ការចល័តទ័ពនៅតាមបណ្ដោយព្រំដែន ។ល។ ស្របពេល ដែលបានព្រមព្រៀងថា រក្សាភាពស្ងប់ស្ងាត់ខាងយោធានោះ) ។

គួររំលឹក និងគួសបញ្ជាក់ថា សៀមធ្លាប់មិនគោរពកិច្ចសន្យាជាមួយភាគីកម្ពុជា ក៏ដូចជាជាមួយអន្តរជាតិផងដែរ ក្នុងពេលកន្លងមក ។ សូមលើកតែពីរចំណុច :

- ដូចក្នុងអំឡុងឆ្នាំ១៩៥៩ សៀមបានប្រកាសបដិសេធថា ប្រទេសខ្លួនមិនមែនជាសមាជិកប្រទេស ដែលទទួលស្គាល់សមត្ថកិច្ចតុលាការយុត្តិធម៌អន្តរជាតិ ក្រុងឡាអេ នោះទេ ការប្រកាសបែបនេះ ដើម្បីដកខ្លួនឱ្យផុតចេញអំពីអំណាចរបស់តុលាការនេះ ក្នុងការកាត់សេចក្ដីវិវាទ រឿងប្រាសាទព្រះវិហារក្នុងឆ្នាំ ១៩៦២ តែទីបំផុតត្រូវអាម៉ាស់ ដោយគេបានរកឃើញថា ប្រទេសសៀមក៏ជាប្រទេសហត្ថលេខីទទួលស្គាល់សមត្ថកិច្ចតុលាការយុត្តិធម៌នេះដែរ ។ នោះគឺជាការកាត់សេចក្ដីទី ១ ដែលបញ្ជាក់ថាប្រទេសសៀមស្ថិតនៅក្រោមសមត្ថកិច្ច តុលាការយុត្តិធម៌អន្តរជាតិ ត្រូវបានប្រកាសក្នុងឆ្នាំ១៩៦១ ។

- ក្នុងកិច្ចប្រជុំជាអន្តរជាតិមួយ ដឹកនាំដោយ លោក *វីល្លីយ៉ាម (Williams)* នៅវ៉ាស៊ីងតោន សហរដ្ឋអាមេរិក ដែលមានប្រទេសចំនួន ៥ ចូលរួម ប្រទេសសៀមធ្លាប់ប្រកាសបដិសេធ និងមិនគោរពនូវអ្វី ដែលជាកិច្ចព្រមព្រៀងអន្តរជាតិលើសន្ធិសញ្ញាឆ្នាំ ១៩០៤ ១៩០៧, ១៩២៥, ១៩៣៧, និងកិច្ចព្រមព្រៀង ឆ្នាំ១៩៤៦ រវាងបារាំង-សៀម ស្ដីពីកម្ពុជានាឆ្នាំ១៩៤៧ ។

ទម្លាប់ផ្លាស់ប្ដូរពាក្យសន្យា ការជាន់ឈ្លីរំលោភលើច្បាប់អន្តរជាតិ និងមិនគោរពហត្ថលេខារបស់ខ្លួនរបៀបនេះ នៅតែបន្តមកទៀត ។ មួយវិញទៀត ថៃក៏នៅតែរក្សាអាកប្បកិរិយាជាប្រទេសឈ្លានពានទឹកដីខ្មែរជាប់ជានិច្ច ដែលយើងពុំអាចទុកចិត្តបានឡើយ ។

## ***មហិច្ឆតារបស់ថៃ : អតីតកាល និងបច្ចុប្បន្នកាល***

ជម្លោះប្រាសាទព្រះវិហាររវាងកម្ពុជា និងសៀមមិនមែនទើបតែកើតមាននាពេលបច្ចុប្បន្ននេះទេ ។ ជម្លោះនេះកាន់តែធ្វើឱ្យមានក្ដីបារម្ភខ្លាំងឡើងៗ នៅពេលដែលប្រាសាទជាទីសក្ការៈរបស់ខ្មែរ ត្រូវបានទទួលស្គាល់ជាផ្លូវការពីសំណាក់គ្រប់ស្ថាប័នអន្តរជាតិ ថាជាកម្មសិទ្ធិរបស់កម្ពុជា ។ តែប្រទេសសៀមនៅតែបន្តចាត់ទុកថា ប្រាសាទព្រះវិហារជារបស់ខ្លួន និងប្រើប្រាស់ទាំងកម្លាំងយោធា ដើម្បីកាន់កាប់ដែនដីរបស់កម្ពុជាដោយគ្មានខ្មាសអៀនរអា ចំពោះអធិបតេយ្យភាពជាតិរបស់កម្ពុជា និងច្បាប់អន្តរជាតិ ដែលមានចែងក្នុងសន្ធិសញ្ញាផ្សេងៗរបស់អង្គការសហប្រជាជាតិ ។

ជាយូរយារណាស់មកហើយ ប្រទេសសៀមមិនដែលលាក់លៀមពីមហិច្ឆតាចង់បានប្រាសាទព្រះវិហារនេះទេ ។ លើសពីនេះទៅទៀត ប្រទេសជិតខាងនេះមិនដែលភ្លេចខេត្តខ្មែរមួយចំនួននៅភាគខាងជើង (ស្ទឹងត្រែង កំពង់ធំ និងបាត់ដំបង) ដែលខ្លួនត្រូវបង្ខំចិត្តប្រគល់ជូនខ្មែរវិញ នាដើមសតវត្សរ៍ទី ២០ ទេ ។

ក៏ប៉ុន្តែ ប្រទេសសៀមមិនធ្លាប់ដែលរំលឹកទាល់តែសោះអំពីទឹកដីខ្មែរ ដែលខ្លួនបានរំលោភយកទៅ និងដាក់ធ្វើក្រោមចំណុះរបស់ខ្លួនកាលពីអតីតកាល ។ គេរឹតតែធ្វើជាភ្លេចថែមទៀតអំពីវត្តមានជនជាតិខ្មែររាប់លាននាក់ ដែលរស់នៅក្នុងបណ្ដាខេត្តភាគឦសានប្រទេសសៀមបច្ចុប្បន្ន ហើយដែលប្រជាជនទាំងនោះនៅតែរក្សាបានយ៉ាងខ្ជាប់ខ្ជួននូវវប្បធម៌ ទំនៀមទម្លាប់

និងអរិយធម៌ខ្មែរជារៀងរហូតមក។ មិនតែប៉ុណ្ណោះ ប្រទេសថៃមិនដែលបានទទួលស្គាល់ថា ខ្លួនបានខ្ចីភាសា វប្បធម៌ និងអរិយធម៌ខ្មែរនោះឡើយ។ ថៃភ្លេចទៀតថា ប្រទេសរបស់ខ្លួនទើបតែកើតឡើងនៅសតវត្សរ៍ទី ១៣ ដោយការដណ្ដើមយកទឹកដីខ្មែរ។

នៅតាមសាលារៀន គេអាចកត់សម្គាល់ឃើញ អ្នកដឹកនាំសៀម បំភ្លេចវត្តមានប្រទេសកម្ពុជាទាំងស្រុងតែម្ដង។ នៅក្នុងការសិក្សាសាលារដ្ឋ រយៈពេល ៩ ឆ្នាំដំបូង សៀវភៅសិក្សារបស់សៀមនិយាយអំពីសិល្បៈខ្មែរ និងអម្បូរខម (ខ្មែរ) តែពីរបីបន្ទាត់ប៉ុណ្ណោះ។ តែសៀវភៅទាំងនោះបែរជាលើករៀបរាប់អំពីវប្បធម៌ និងអរិយធម៌របស់ប្រទេសផ្សេងៗ សូម្បីតែនៅឆ្ងាយៗពីគេដ៏ដោយ។ ដូច្នេះ អ្វីៗទាំងអស់ ហាក់បីដូចជាធ្វើ និងរៀបចំឡើង ដើម្បីបំបាត់រាល់ប្រវត្តិសាស្ត្រពិតរបស់កម្ពុជា បំបាត់ឥទ្ធិពលរបស់អាណាចក្រខ្មែរ ដែលធ្លាប់ជា "ម្ចាស់" លើទឹកដីថៃបច្ចុប្បន្ន។ ត្រង់នេះយើងអាចយល់ឃើញថា សៀមមានចំណុចខ្សោយ ដែលជាអតីតកាលរបស់ខ្លួន ដែលចងភ្ជាប់នឹងប្រវត្តិសាស្ត្រវប្បធម៌អរិយធម៌ខ្មែរ និងជាពិសេសទៅនឹងទឹកដីរបស់ខ្មែរ ដែលសៀមបានឈ្លានពានដណ្ដើមយកពីសតវត្សរ៍ទី ១៣ នៃគ្រិស្ដសករាជ។

មហិច្ឆតាវាតទឹកដីរបស់ថៃ ឬ Pan-Thai ត្រូវបានលោក **Francis Lacoste** តំណាងប្រទេសបារាំង នៅសន្និសីទអន្តរជាតិ នៅទីក្រុងវ៉ាស៊ីនតុន បានសរសេរកត់ត្រាជាសាធារណៈនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៤៧ ថា : "*គណបក្សនយោបាយយោធាសៀម បានបង្កើតទ្រឹស្ដីវាតទីនិយមនេះនៅក្នុងឆ្នាំ ១៩៣៧ ដើម្បីឈានទៅយកអំណាច។ ពីពេលនោះមក ទ្រឹស្ដីវាតទីនិយមចេះតែរីកចម្រើន បានទទួលជោគជ័យជាលំដាប់ ហើយបានជំរុញឱ្យសៀមមានមហិច្ឆតាចង់ គ្របដណ្ដប់មកលើប្រទេសជិតខាង*"។

យើងអាចកំណត់មហិច្ឆតាវាតទីនិយម (Expansion-nisme) នេះតទៅ :

### ១- សន្ធិសញ្ញាតូក្យូឆ្នាំ ១៩៤១

សៀមបានកាន់កាប់ប្រាសាទព្រះវិហារជាទីសក្ការៈ ពីឆ្នាំ ១៩៤១ ដល់ឆ្នាំ ១៩៤៦។

ក្នុងឆ្នាំ ១៩៤១ ក្នុងសម័យសង្គ្រាមលោកលើកទី ២ (១៩៣៩-១៩៤៥) ប្រទេសសៀមបានចងសម្ព័ន្ធមេត្រីភាពចូលក្នុងក្រុមប្រទេសជប៉ុន។ ដោយសំអាងលើកម្លាំងទ័ព និងជ័យជំនះរបស់ជប៉ុនទៅលើបារាំង សៀមបានបង្ខំឱ្យបារាំងប្រគល់ទឹកដីខ្មែរនៅភូមិភាគខាងជើងទៅឱ្យខ្លួន។ គ្រានោះ សៀមបានកាន់កាប់ប្រាសាទព្រះវិហារជាទីសក្ការៈពីឆ្នាំ ១៩៤១ ដល់ឆ្នាំ ១៩៤៦។

### ២-ក្នុងឆ្នាំ១៩៤៧

ក្នុងសន្និសីទអន្តរជាតិ នៅទីក្រុងវ៉ាស៊ីងតោន ដែលប្រព្រឹត្តទៅតាមសន្ធិសញ្ញាវ៉ាស៊ីងតោន ឆ្នាំ ១៩៤៦ ត្រង់មាត្រា ៣ ព្រះអង្គម្ចាស់ *សកល វរវ័ណ្ណ (Prince Sokol Varavorn)* បានទាមទាឱ្យសើរើសន្ធិសញ្ញា ដែលខ្លួនបានចុះហត្ថលេខាយល់ព្រមជាមួយប្រទេសបារាំង តំណាងប្រទេសកម្ពុជា ឆ្នាំ ១៨៩៣ ១៩០៤ និង ១៩០៧ ។

**៣-ពីឆ្នាំ ១៩៤៩ ដល់ ឆ្នាំ ១៩៦២** : ប្រទេសថៃបានឈ្លានពានត្រួតត្រាកាន់កាប់ប្រាសាទព្រះវិហារ និងតំបន់ជិតជុំវិញ។

**៤-ឥឡូវនេះពីថ្ងៃទី១៥ កក្កដា ឆ្នាំ ២០០៨ :** ដោយមិនគោរពសន្ធិសញ្ញាអន្តរជាតិ និងច្បាប់អន្តរជាតិ ដែលខ្លួនបានទទួលស្គាល់ ប្រទេសថៃបានឈ្លានពានរំលោភទឹកដីខ្មែរទៀតនៅតំបន់ប្រាសាទព្រះវិហារ ប្រាសាទតាមាន់ ប្រាសាទតាក្របី និងតាមជួរភ្នំដងរែក។

ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងនយោបាយ ដូចដែលយើងបានលើកមកខាងលើ អាចបញ្ជាក់បានយ៉ាងច្បាស់លាស់ថា ទ្រឹស្ដីវាតទីទឹកដីរបស់ថៃស្ថិតនៅជានិច្ចនិរន្តរ៍ក្នុងទឹកចិត្ត គោលជំហរ ខ្លឹមសារនយោបាយរបស់គេ ជាពិសេស ចំពោះប្រទេសកម្ពុជា។

## *គោលការណ៍សើរើសន្ធិសញ្ញាអន្តរជាតិ*

មហិច្ឆតាសៀម ត្រូវបានចងភ្ជាប់ទៅនឹងសន្ធិសញ្ញាទាំងប៉ុន្មាន ដែលខ្លួនធ្លាប់បានចុះហត្ថលេខា និងទទួលស្គាល់ជាសាធារណៈជាមួយប្រទេសបារាំង តំណាងឱ្យព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ សៀមត្រូវរៀបចំដូចម្ដេច ដើម្បីបំភ្លេច បំភាន់មតិ បន្លំ ឬធ្វើជាច្រឡំលុបចោលអ្វីទាំងអស់ ដែលជាចំណុចខ្សោយរបស់ខ្លួន។

### ១-សន្ធិសញ្ញាបារាំង-សៀម

នៅក្នុងទស្សនៈ និងគោលការណ៍នេះ សៀមបានបង្កើតទ្រឹស្ដី Pan-Thai (ថៃធំ) ទ្រឹស្ដីវាតទីនិយម (Expansionnisme) និងឆ្លៀតគ្រប់ឱកាស ដើម្បីសើរើគ្រប់សន្ធិសញ្ញា ដែលធ្លាប់យល់ ព្រមចុះហត្ថលេខាជាមួយនឹងប្រទេសបារាំង ដែលជាប្រទេសអាណាព្យាបាលតំណាងព្រះរាជាណាចក្រកម្ពុជា។

សន្ធិសញ្ញាទាំងនោះមានជាអាទិ៍ :

- ឆ្នាំ១៩០៤ (១៣/០២/០៤)
- ឆ្នាំ ១៩០៧ (២៣/០៣/០៧)
- ឆ្នាំ ១៩២៥
- ឆ្នាំ ១៩៣៧
- ឆ្នាំ ១៩៤៦ ជាដើម ។ល។

### ២-សាលក្រមតុលាការយុត្តិធម៌អន្តរជាតិ (Cour Internationale de Justice, CIJ)

បន្ថែមពីលើសន្ធិសញ្ញាខាងលើ សៀមត្រូវការរកគ្រប់វិធី ដើម្បីកំទេចសាលក្រមតុលាការយុត្តិធម៌អន្តរជាតិ ក្រុងឡាអេ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៦២ ។

យើងសូមរំលឹកថា សាលក្រមនោះមានពីរចំណែក :

- ឆ្នាំ ១៩៦១ (២៧/០៥/៦១) ដែលទទួលស្គាល់ ថា តុលាការយុត្តិធម៌អន្តរជាតិ មានសមត្ថកិច្ច និងអំណាចគ្រប់គ្រាន់ ក្នុងការកាត់ក្តីវិវាទកម្ពុជា-សៀម ។

- ឆ្នាំ ១៩៦២ (១៥/០៦/៦២) ដែលកាត់ក្តីឱ្យខ្មែរ ឈ្នះថៃក្នុងសំណុំរឿងប្រាសាទព្រះវិហារ ។ គឺប្រាសាទព្រះវិហារ ស្ថិតក្នុងអធិបតេយ្យភាពខ្មែរ និងបូរណភាពទឹកដីខ្មែរ ។

## *មហិច្ឆតាចាស់ យុទ្ធសាស្ត្រថ្មី*

ការសម្រេចរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក របស់អង្គការយូណេស្កូ កាលពីថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០៨ កន្លងទៅនេះ គឺជាសាលដីកាលើកទីពីរ ដែលចេញដោយ សហគមន៍អន្តរជាតិប្រឆាំងនឹងសៀម ហើយទទួលស្គាល់អធិប-តេយ្យភាព និងបូរណភាពទឹកដីខ្មែរ ។ សេចក្តីសម្រេចរបស់ សហគមន៍អន្តរជាតិនេះ បានបញ្ចប់មហិច្ឆតាវាតទីនិយមរបស់ ថៃ ។ ដូច្នេះសៀមត្រូវសហគមន៍អន្តរជាតិថ្កោលទោសជាលើកទី ២ ហើយ ។ ប៉ុន្តែប្រទេសសៀមនៅតែមិនអស់ចិត្ត ហើយបាននាំ គ្នារំលោភលើគ្រប់សន្ធិសញ្ញា សាលក្រម និងសេចក្តីសម្រេច គ្រប់បែបយ៉ាង ដើម្បីរកលេសដណ្តើមយកប្រាសាទព្រះវិហារ និងឈ្លានពានរំលោភទឹកដីខ្មែរ ។

*ការឈ្លានពានរបស់សៀម មកលើអធិបតេយ្យភាព និង បូរណភាពទឹកដីខ្មែរ* កើតឡើងចំពេល ដែលសៀមកំពុងតែមាន វិបត្តិនយោបាយផ្ទៃក្នុង ដែលគេមើលឃើញតាមរយៈការកើត មានបាតុកម្មឥតឈប់ឈរក្នុងប្រទេស ។ ឆ្លៀតឱកាសដ៏ល្អនេះ បក្សប្រឆាំងសៀម បានប្រើប្រាស់ករណីប្រាសាទព្រះវិហារខ្មែរ ធ្វើ ជាប្រធានបទឃោសនា ដើម្បីទាក់ទាញក្រុមអ្នកប្រឆាំង និង រដ្ឋាភិបាលរបស់លោក *សាម៉ាក់ សុនដារ៉ាវេត* ដែលកើត ចេញពីការបោះឆ្នោត ឆ្នាំ ២០០៧ ។

ប៉ុន្តែក្រោយមក បានឆ្លៀតយកឱកាសនេះ អ្នកដឹកនាំ សៀម (អាចជា *សាម៉ាក់* ខ្លួនឯងផ្ទាល់ អាចជាមេទ័ពជាន់ខ្ពស់ សៀម ឬអាចជាទ័ពចោរព្រៃ) បានប្រើប្រាស់សំណុំរឿងប្រាសាទ ព្រះវិហារ ដើម្បីបញ្ជូនកងទ័ពទាហានសៀមឱ្យមកឈ្លានពាន បោះទីតាំងនៅតំបន់ប្រាសាទព្រះវិហាររបស់ខ្មែរ ប្រាសាទតាមាន់ធំ តាមាន់ តូច និងតាក្របី និងតំបន់ជួរភ្នំដងរែករបស់ខ្មែរ ។

## *យុទ្ធសាស្ត្រ យកខ្មែរសម្លាប់ខ្មែរ*

នៅក្នុងនយោបាយឈ្លានពានកាន់កាប់ទឹកដីខ្មែរនេះ សៀម បានដាក់ទាហាន ដែលមានដើមកំណើតខ្មែរឱ្យឈរនៅជួរមុខ ទល់នឹងក្រុមទាហានខ្មែរ ។ ដូច្នេះ ក្នុងករណី ដែលមានសង្គ្រាម ផ្ទុះឡើងដោយថាហេតុរវាងប្រទេសទាំងពីរ ខ្មែរទាំងពីរក្រុម នឹងសម្លាប់គ្នាទៅវិញទៅមកជាមិនខាន ។ ដល់ពេលនោះ គំនុំ ការសងសឹក និងការទាស់ទែងបែកបាក់គ្នា នៅក្នុងចង្កោមពូជ សាសន៍ខ្មែរ នឹងបន្តស្ថិតនៅរវាងខ្មែរ និងខ្មែរជារៀងរហូត ។

ព្រឹត្តិការណ៍ឈ្លានពានទឹកដីកម្ពុជា ចុងក្រោយនេះធ្វើឱ្យ គេយល់ឃើញថា អ្នកនយោបាយសៀមគ្រប់ជាន់ថ្នាក់ ទាំងអស់ ចេះបែងចែកគ្នាធ្វើកិច្ចការយ៉ាងល្អ និងបង្កើតឆាកល្ខោន ដើម្បី បំភាន់មតិជាតិខ្មែរ និងមតិសហគមន៍អន្តរជាតិ ។

## *យុទ្ធវិធីពន្យារពេលចរចា*

បន្ទាប់ពីបានរំលោភបំពានឈ្លានពាន និងឈរជើងលើ ទឹកដីខ្មែរ ការចរចាអំពីបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ ក៏ ចាប់ផ្តើមឡើង ។ តែបើពិនិត្យមើលឱ្យជិតបន្តិចទៅកិច្ចចរចា នេះ ហាក់ដូចជាផ្តល់ប្រយោជន៍យ៉ាងច្រើន ទៅឱ្យភាគីសៀម ដែលឆ្លៀតកេងប្រវ័ញ្ចយកចំណេញពីភាពទន់ភ្លន់ និងនយោបាយ សន្តិវិធីរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ជំនួបប្រជុំនៅថ្ងៃទី ២១ ២៨ កក្កដា និងថ្ងៃទី ១៨-១៩ សីហា ឆ្នាំ ២០០៨ កន្លងទៅ នេះ មិនបានផ្តល់លទ្ធផលអ្វីជាក់លាក់នោះទេ ។ ភាគីថៃបាន ប្រែក្រឡាស់ពាក្យសម្តី និងបោះសម្តីអមិត្តគ្រប់បែបយ៉ាង ទាំងអស់ ដើម្បីពន្យារការចរចាទ្វេភាគី ។ ជាងនេះទៅទៀត ប្រទេសនេះបានព្យាយាមរកហេតុផលផ្សេងៗមកធ្វើជាលេស ។

សៀមបានពន្យារពេលចរចា ដើម្បីចំណេញពេលវេលា។ នេះមិនមែនជាល្បិចថ្មីទេឬ? សៀមធ្លាប់ប្រើប្រាស់ល្បិចនេះ រួចមក ហើយ នៅក្នុងអំឡុងពេលចរចាអំពីសំណុំរឿងប្រាសាទព្រះវិហារ នៅក្នុងទសវត្សរ៍មុនៗ ។ សៀមបានប្រើល្បិចកលនេះ អូសបន្លាយ ពេលតាំងតែពីឆ្នាំ ១៩៥៤ រហូតដល់ឆ្នាំ ១៩៦២ ។ សៀមយល់ថា ពេលវេលានឹងជួយឱ្យគេចំណេញច្រើន ក្នុងផ្នែកនយោបាយ និង មហិច្ឆតាវាតទឹកដី ។

## *គោលបំណង*

គោលបំណងនៃយុទ្ធសាស្ត្ររបស់សៀមសព្វថ្ងៃនេះគឺចង់ :

- បញ្ឈប់ការថ្កោលទោសរបស់ក្រុមប្រឹក្សាសន្តិសុខ សហប្រជាជាតិ និងការថ្នាំងថ្នាក់របស់សហគមន៍ អន្តរជាតិ

- ស្ដារស្ថានការណ៍នយោបាយ ក្នុងការចូលឈ្លានពានកម្ពុជា និងស្ដារមុខមាត់ចក្រពត្តិនិយមថ្មីរបស់ខ្លួន
- ស្ដារផលប្រយោជន៍ជាច្រើនឡើងវិញ នៅលើឆាកអន្តរជាតិ
- រម្ងាប់ប្រតិកម្មរបស់មតិអន្តរជាតិ និងធ្វើឱ្យសហគមន៍អន្តរជាតិភ្លេចបញ្ហាចូលឈ្លានពានប្រទេសកម្ពុជា
- ពន្យារពេលការឈរជើងនៅលើទឹកដីខ្មែរ ដើម្បីឈានទៅរកកាន់កាប់ទឹកដីខ្មែរទាំងស្រុងតែម្ដង។
- មិនតែប៉ុណ្ណោះយុទ្ធសាស្ត្រសៀម ដែលប្រើពេលវេលាជាឧបករណ៍ និងធ្វើឱ្យប្រជាពលរដ្ឋខ្មែររសាយចិត្តភ្លេចរឿងទឹកដី និងមានសតិអារម្មណ៍មិនពេញចិត្ត នឹងនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ចំណុចដែលគួរពិចារណា

នៅក្នុងបញ្ហាប្រទេសសៀមឈ្លានពាន មកលើអធិបតេយ្យភាព និងបូរណភាពទឹកដីប្រទេសកម្ពុជា និងនយោបាយវាតទឹកដីរបស់ជីរបស់ចក្រពត្តិថ្មីនេះ យើងមានចំណុចជាច្រើនដែលគួរលើកយកមកពិចារណា:

១- តើសហគមន៍អន្តរជាតិ និងប្រទេសសមាជិកអាស៊ានគិតយ៉ាងដូចម្ដេចអំពីបញ្ហានេះ? មកដល់សតវត្សរ៍ទី ២១ ទៅហើយ តើគេអាចបណ្ដោយឱ្យថៃឈ្លានពានមកលើអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ដែលជាសមាជិកអង្គការសហប្រជាជាតិ និងអាស៊ានដែរឬយ៉ាងណា?

២- តើសហគមន៍អន្តរជាតិអាចជឿទុកចិត្ត និងធ្វើសហប្រតិបត្តិការជាមួយប្រទេសសៀម ដែលមានមហិច្ឆតាវាតទីនិយម ជាន់ឈ្លីសន្ធិសញ្ញាអន្តរជាតិ និងមិនគោរពតាមកិច្ចសន្យារបស់ខ្លួននោះដែរឬទេ?

៣- តើការដែលក្រុមទាហានសៀមចូលលុកលុយ ឈ្លានពានកាន់កាប់ទឹកដីខ្មែរ អាចបញ្ចប់វិវាទផ្ទៃក្នុងនៅប្រទេសខ្លួនបានដែរឬទេ?

៤- តើការចចារកម្ពុជា-សៀម អាចឈានទៅរកភាពជោគជ័យ និងយុត្តិធម៌ឬទេ?

៥- តើនាយករដ្ឋមន្ត្រីថ្មី លោក *ស៊ុមឆៃ វង្សសាវ៉ាត* ដែលស្ថិតនៅក្នុងចង្កោមលោកអតីតនាយករដ្ឋមន្ត្រី *ថាក់ស៊ីន* និងលោក *សាម៉ាក់* អាចដោះស្រាយ និងបន្តការចរចានេះ បានឬទេ? បើក្រុមអ្នកប្រឆាំងនៅតែប្រឆាំងដដែល?

ទោះជាយ៉ាងណា យើងគួររំលឹកថា សៀមជាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី ២១ ឆ្នាំ តុលា ឆ្នាំ ១៩៩១ ស្ដីពីដំណោះស្រាយនយោបាយរួមនៅកម្ពុជា ដោយសន្យាថា គោរពព្រំដែនកម្ពុជា។

អាកប្បកិរិយាក្រអឺតក្រទមរបស់សៀមបែបនេះ អាចបំផ្លាញទំនាក់ទំនងនៅក្នុងសមាគមអាស៊ាន និងបណ្ដាលឱ្យមានការខូចខាតជាច្រើនទៅថ្ងៃអនាគត។

ទន្ទឹមគ្នានោះ ទំនាក់ទំនងទៅថ្ងៃមុខរវាងប្រជាពលរដ្ឋខ្មែរ និងសៀម អាចនឹងមានភាពល្អក់កករ ដោយសារតែមហិច្ឆតា និងភាពក្រអឺតក្រទមរបស់អ្នកនយោបាយសៀម។ សៀមភ្លេចហើយថា កម្ពុជាគឺជាទីផ្សារដ៏ធំមួយសម្រាប់ផលិតកររបស់ខ្លួន។

ក្នុងសភាពការណ៍បច្ចុប្បន្ន ប្រទេសកម្ពុជាមានតែរួចខ្លួន និងខាតតែប៉ុណ្ណោះ។ ចំណែកឯភាគីថៃ មានតែចំណេញនឹងរួចខ្លួន។

សម្រាប់ពុទ្ធសាសនិកខ្មែរ អ្នកមានជំនឿទៅលើបុណ្យបាប ការចូលឈ្លានពានរបស់ថៃ និងកាន់កាប់តំបន់ជាទីសក្ការៈប្រាសាទព្រះវិហារ ដែលជាកម្មសិទ្ធិរបស់ខ្មែរនេះ គឺជាការប្រព្រឹត្តខុសឆ្គងដ៏ធំមួយនៅក្នុងប្រវត្តិសាស្ត្រ និងជំនឿរបស់ខ្លួន។ នៅក្នុងគតិ និងជំនឿរបស់ពុទ្ធសាសនិកខ្មែរ បានធ្វើ និទស្សន៍ថា នាពេលអនាគត នៅប្រទេសថៃនឹងមានវិបត្តិផ្ទៃ ក្នុងកាន់តែធ្ងន់ធ្ងរខ្លាំងជាងនេះ ជាក់ជាមិនខាន។

## បណ្ឌិត សុខ ទូច : ពេលនេះ ជាពេលខ្មែរត្រូវរួបរួមគ្នា



សាស្ត្រាចារ្យបណ្ឌិត សុខ ទូច

ក្នុងខណៈដែលមានការឈ្លានពានជាបន្តបន្ទាប់ ពីសំណាក់ទាហានសៀម សាស្ត្រាចារ្យបណ្ឌិត *សុខ ទូច* អនុប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា និងជាសាស្ត្រាចារ្យវិទ្យាសាស្ត្រនយោបាយ បានបញ្ចេញទស្សនៈថា ពេលនេះជាង ពេលណាៗទាំងអស់ ដែលខ្មែរទាំងអស់ត្រូវរួបរួមគ្នាក្នុងជំហរតែមួយ ក្នុងការការពារទឹកដីខ្មែរយើង ដោយមិនត្រូវបណ្ដោយឱ្យបរទេស ចូលមកឈ្លានពានដោយខុសច្បាប់នោះទេ ហើយប្រទេសសៀម ត្រូវតែគោរពអធិបតេយ្យភាពជាតិខ្មែរ សៀមត្រូវតែដកទាហានរបស់ខ្លួនចេញពីទឹកដីខ្មែរជាបន្ទាន់ដោយគ្មានលក្ខខណ្ឌ។ ថៃបានរំលោភ

យ៉ាងធ្ងន់ធ្ងរចំពោះសាលក្រមតុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៦២ ក៏ដូចច្បាប់ និងកាតព្វកិច្ចជាអន្តរជាតិនានា" ។

បទពិសោធន៍ប្រវត្តិសាស្ត្របានបង្ហាញថា សៀមជាប្រទេសពោរពេញដោយល្បិច ហើយមិនសូវគោរពនូវអ្វី ដែលខ្លួនសន្យានោះទ។ ប្រទេសនេះនិយាយផ្សេង ធ្វើផ្សេង។ ចំណុចនេះកម្ពុជាត្រូវមានការប្រុងប្រយ័ត្នឱ្យមែនទែនរាល់ការសម្រេចចិត្តណាមួយជាមួយប្រទេសនេះ។ ជាពិសេសក្នុងការចរចាបញ្ហាព្រំដែនជាមួយសៀម កម្ពុជាត្រូវប្រកាន់ជំហរឱ្យបានរឹងមាំក្នុងការប្រើប្រាស់ផែនទី ដែលជាឧបសម្ព័ន្ធនៃសាលក្រមតុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ១៩៦២ ជាមូលដ្ឋានក្នុងការកំណត់ព្រំដែនជាមួយសៀម។

លោកបណ្ឌិត *សុខ ទូច* បានលើកឡើងថា «*រស់ក្នុងសន្តិភាព ត្រូវត្រៀមខ្លួនធ្វើសង្គ្រាម ប៉ុន្តែពុំមែនសង្គ្រាមជាតិសាសន៍ឯងនោះទេ គឺការត្រៀមខ្លួនធ្វើសង្គ្រាមជាមួយបរទេសឈ្លានពាន។ ដូច្នេះ ការហ្វឹកហាត់ ការបណ្ដុះបណ្ដាលកងទ័ពការពារព្រំដែន និងរៀបចំលក្ខណៈត្រៀមប្រយុទ្ធ ជាភារកិច្ចសំខាន់បំផុតរបស់ក្រសួងការពារជាតិ ដែលមិនត្រូវធ្វេសប្រហែសបានឡើយ។ ជាមួយគ្នានោះដែរ ការឧបត្ថម្ភ និងផ្គត់ផ្គង់ កងទ័ពត្រូវធ្វើឱ្យបានសមរម្យ។ កងទ័ពត្រូវមានវិន័យ ឯកសណ្ឋាន និងយុទ្ធោបករណ៍គ្រប់គ្រាន់។ ទោះបី ប្រទេសយើង មានសន្តិភាពពិតមែន តែបរទេសជិតខាងនៅតែមានគំនិតឈ្លានពានរំលោភទឹកដីយើងគ្រប់ពេលវេលា ដូច្នេះកងទ័ពការពារព្រំដែនកម្ពុជាត្រូវត្រៀមប្រយុទ្ធជានិច្ច ហើយយុវជនកម្ពុជាគ្រប់រូបត្រូវត្រៀមខ្លួនបំពេញកាតព្វកិច្ចយោធា តាមតម្រូវការរបស់ប្រទេសជាតិ។ យើងស្រលាញ់សន្តិភាព តែយើងមិនខ្លាចសង្គ្រាមឈ្លានពានទេ។ ខ្មែរត្រូវតែខ្លាំង ខ្មែរត្រូវតែរឹងមាំ ខ្មែរត្រូវមានការអភិវឌ្ឍ ឱ្យតែខ្មែររួបរួមគ្នា និងស្រលាញ់គ្នា។*»








**ទិដ្ឋភាពប្រាសាទព្រះវិហារជាទីសក្ការៈរបស់ខ្មែរ**



ភ្នំព្រះវិហារមើលពីចម្ងាយរាងដូចបល្ល័ង្ក ដែលពោរពេញដោយបារមី



ក្បាលនាគដ៏ប្រកបដោយមហិទ្ធិឫទ្ធិ





សកម្មភាពថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា នាំយកសម្ភារ និងថវិកា ប្រគេនព្រះសង្ឃ និងជូនអាជ្ញាធរ និងប្រជាពលរដ្ឋ នៅតំបន់ប្រាសាទព្រះវិហារ កាលពីថ្ងៃទី ២៨-២៩ ខែ កក្កដា ឆ្នាំ ២០០៨